មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ សុខ យឿន ភេទស្រី អាយុ៦១ឆ្នាំ**

**មុខងារជំនាន់ខ្មែរក្រហមៈ «អនុសេនាតូច»**

**ស្រុកកំណើតនៅភូមិសុភី ឃុំអន្លង់វិល ស្រុកថ្ងាំង ខេត្តតាកែវ**

**សព្វថ្ងៃនៅភូមិស្រះជ្រៃ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០១:២៧:៣០**

**២៩ទំព័រ**

វណ្ណៈ ចឹងថ្ងៃហ្នឹងថ្ងៃទី២៨ខែ១១ឆ្នាំ២០១៣ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំបានមកភូមិឃុំនេះគឺចឹងដឹងរឿងរ៉ាវកន្លងមកតាំងពីអតីតកាល កាលមីងនៅពីតូចរៀនបានត្រឹមណាហើយធ្លាប់បានឆ្លងកាត់អ្វីខ្លះ? រហូតបានមករស់នៅព្រំដែននេះ ចឹងអ្វីដែលមីងអាចចាំបាននិងអ្វីដែលមីងមិនអាចចាំបានក៏មិនអីដែរ ចឹងបទសំភាសខ្ញុំជាមួយមីងហ្នឹងតើមីងអាចឲ្យខ្ញុំយកទៅប្រើការបានទេ ទុកប្រើជាប្រវត្តិសាស្ត្រមីងមិនថាអីទេមីង?

យឿនៈ ចាស ។

វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ មីង មីងឈ្មោះអីដែរ?

យឿនៈ ខ្ញុំឈ្មោះ សុខ យឿន ។

វណ្ណៈ មីងអាយុប៉ុន្មានហើយ?

យឿនៈ អាយុ៦១ឆ្នាំ ។

វណ្ណៈ ប្តីមីងឈ្មោះ អីដែល?

យឿនៈ ឈ្មោះ ព្រំ យឹម ។

វណ្ណៈ អាយុគាត់ប៉ុន្មានដែរ?

យឿនៈ អាយុ៦៣ឆ្នាំ ។

វណ្ណៈ មីងមានកូនចៅទាំងអស់ប៉ុន្មាននាក់?

យឿនៈ មាន៧នាក់ ។

វណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

យឿនៈ ប្រុស៣ស្រី៤ ។

វណ្ណៈ ចឹងកូនទាំង៧នាក់ហ្នឹង សព្វថ្ងៃបានរៀបការហើយខ្លះឬនៅ?

យឿនៈ មានគ្រួសារហើយ៣នាក់ហើយ ចេញហើយ ។

វណ្ណៈ ចឹងបានរៀបការបីនាក់ហើយ តើពួកគាត់រស់នៅក្នុងភូមិហ្នឹងដែលឬមួយរស់នៅភូមិផ្សេង?

យឿនៈ កូនខ្ញុំនៅជិតៗហ្នឹង នោះផ្ទះតៗគ្នាហ្នឹង ។

វណ្ណៈ កូនមីងមានរៀនបានច្រើនទេ?

យឿនៈ រៀនបានតិចៗ រៀនបានត្រឹមថ្នាក់ទី១១ ទី១០ ទី៩ ទី៨ ។

វណ្ណៈ ចឹងមានមូលហេតុអីបានជាពួកគាត់ត្រឹមហ្នឹង?

យឿនៈ ឈប់រៀនដោយសារឪពុកម្ដាយក្រ ម្យ៉ាងឪពុកឈឺទើបបានធូ គ្មានពីណាធ្វើអាជីវកម្មចិញ្ចឹមឪពុកម្ដាយ ។

វណ្ណៈ ចឹងកូនទាំងអស់ហ្នឹងសម្រេចចិត្តឈប់ដើម្បីជួយធ្វើការឪពុកម្ដាយ?

យឿនៈ ចាស ។

វណ្ណៈ ចឹងមីងគិតថាការរៀនសូត្រហ្នឹងមានសារៈសំខាន់ទេ?

យឿនៈ ខ្ញុំយល់ថា ការរៀនសូត្រវាជាមាសជាពេជ្រដើម្បីអនាគតកូនវែងឆ្ងាយ តែមកពីយើងខ្វះខាតណាស់ កាលណារៀនដល់ថ្នាក់ខ្ពស់ត្រូវការលុយច្រើន ម្លោះហើយវាអត់មានថវិការដើម្បីផ្ដល់ឲ្យកូន ម្លោះហើយកូនវាមើលឃើញជីវភាពឪពុកម្ដាយជាក់ស្ដែង ចឹងវាសម្រេចថាឲ្យតែមើលអក្សរបាន កុំឲ្យគេមើលងាយប៉ុណ្ណឹងបានហើយម៉ែអើយ ឈប់ដើម្បីធ្វើអាជីវកម្មចិញ្ចឹមគ្រួសារចឹងណាស់ ។

វណ្ណៈ ចឹងពួកគាត់ដែលចេញទៅហ្នឹង តើពួកគាត់មានជីវភាពយ៉ាងម៉េចដែរ?

យឿនៈ អត់អីទេ ហើយអាមួយនោះធ្វើទាហានកាន់ខាងគេអូនោះនៅព្រំដែន ។

វណ្ណៈ នៅព្រំដែនខាងព្រះវិហារ?

យឿនៈ ខាងតាបោងខាងជុបដួរខាងប្រះវិហារដែរ ខាងប្រាសាទតាក្របីអីនោះ ហើយរួចពីហ្នឹងធ្វើស្រែចម្ការ ។

វណ្ណៈ ចឹងគាត់មានជីវភាពខ្វះខាតដែរ?

យឿនៈ អត់ទេ ដោះស្រាយជីវភាពរបស់គេបាន ។

វណ្ណៈ ចឹងកូននៅក្នុងបន្ទុក៤នាក់ទៀតហ្នឹងឈប់រៀនដែរ?

យឿនៈ ឈប់ដែរ ឈប់ឆ្នាំនេះរៀនបានត្រឹមទី៩ ។

វណ្ណៈ ចឹងខ្ញុំចង់សួរពីឪពុកមីងឈ្មោះ អីដែរ?

យឿនៈ ឈ្មោះ អ៊ុក អ៊ី ។

វណ្ណៈ ម្ដាយ?

យឿនៈ ឈ្មោះ ញ៉ែម យ៉ាន់ ។

វណ្ណៈ  សព្វថ្ងៃឪពុកម្ដាយមីងគាត់នៅរស់ដែរ?

យឿនៈ ស្លាប់តាំងពីខ្ញុំអាយុបាន៧ឆ្នាំ ។

វណ្ណៈ  ចឹងមីងមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

យឿនៈ មានបងប្អូនបង្កើត៧នាក់ ។

វណ្ណៈ  ចឹងមានច្រើនដែរ?

យឿនៈ ចាស ។

វណ្ណៈ  ចឹង៧នាក់ហ្នឹងមានស្រីប៉ុន្មានប្រុសប៉ុន្មាន?

យឿនៈ ស្រី៣ប្រុស៤  ស្លាប់អស់ហើយ ។

វណ្ណៈ  សព្វថ្ងៃនៅសល់ប៉ុន្មាននាក់?

យឿនៈ សព្វថ្ងៃតាមខ្ញុំដឹងនៅសល់តែពីរទេ ។

វណ្ណៈ  ចឹង៥នាក់ទៀតស្លាប់ដោយសារអី?

យឿនៈ ស្លាប់ដោយសារឈឺ  ខ្លះស្លាប់កាលពីដើមកាលនៅតូច ។

វណ្ណៈ  ចឹងបងបន្ទូស់ឈ្មោះអីទៅ?

យឿនៈ ឈ្មោះ  សុខ  សាអែម ។

វណ្ណៈ  ទី២ឈ្មោះអី?

យឿនៈ សុខ  អ៊ុម ។

វណ្ណៈ  គាត់នៅរស់ដែរ?

យឿនៈ គាត់រស់នៅស្រុកកំណើត ។

វណ្ណៈ  ទី៣?

យឿនៈ ឈ្មោះ  សុខ  សារឿន ។

វណ្ណៈ  ទី៤?

យឿនៈ ឈ្មោះ  សុខ  យ៉េម ។

វណ្ណៈ  ទី៥?

យឿនៈ ទី៥ខ្ញុំ ។

វណ្ណៈ  ទី៦?

យឿនៈ ឈ្មោះ  សុខ  អូន ។

វណ្ណៈ  ទី៧?

យឿនៈ ឈ្មោះ  សុខ  អ៊ិត ។

វណ្ណៈៈ ចឹងមីងកាលពីតូចមានបានរៀនសូត្រទេ?

យឿនៈ ខ្ញុំរៀនបានតែបន្តិចបន្តួចរៀនបានត្រឹមថ្នាក់ទី១០ ។

វណ្ណៈៈ រៀននៅសាលាបឋមសិក្សាណាដែរ?

យឿនៈ សាលាបឋមសិក្សាវត្តកកោះ ។

វណ្ណៈៈ ចឹងមីងស្រុកកំណើតមីងនៅខាងណាដែរ?

យឿនៈ ភូមិសុភី ឃុំអង្គខ្នុរ ស្រុកទ្រាំង ខេត្តតាកែវ ។

វណ្ណៈៈ ចឹងសព្វថ្ងៃនៅភូមិឃុំអីដែរ?

យឿនៈ នៅភូមិស្រះជ្រៃ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

វណ្ណៈៈ ស្រះជ្រៃហ្នឹងយ៉ាងម៉េចបានជាដាក់ថាស្រះជ្រៃ?

យឿនៈ តាមមើលគេគោលស្រះនេះតែម្ដង កាលពីមុនមានដើមជ្រៃមួយនៅហ្នឹង ចឹងហើយបានជាគេដាក់ភូមិស្រះជ្រៃចឹងតែម្ដង ។

វណ្ណៈៈ ចឹងកាលមីងនៅតូចៗកាលហ្នឹងមីងឈប់រៀននៅឆ្នាំណា?

យឿនៈ មិនបានចាំទេ ។

វណ្ណៈៈ ឈប់មុនរដ្ឋប្រហារឬក្រោយរដ្ឋប្រហារ?

យឿនៈ ឈប់មុន កាលហ្នឹងគិតទៅខ្ញុំរៀនបានតែពីរឆ្នាំទេ កាលហ្នឹងអាយុ១០ឆ្នាំបានរៀន កាលហ្នឹងជួយឃ្វាលគោអីចឹងទៅជួយធ្វើស្រែចម្ការឪពុកម្ដាយ កាលហ្នឹងម្ដាយខ្ញុំគាត់មេម៉ាយណាកំព្រាផង បងៗរៀនចឹងទៅ បងបន្ទុស់រៀនបានទី៨ទី៩ដូចគេថាចឹងណា រៀនតៗពីហ្នឹងទៅ ។

វណ្ណៈៈ ចឹងមានបងរៀនដល់ភ្នំពេញទៀត?

យឿនៈ រៀនដល់ភ្នំពេញ បងដូចជាបានទៅក្រៅប្រទេសទៀត តែដល់សម័យប៉ុល ពត មិនដឹងជារបៀបយ៉ាងម៉េច មិនដឹងជាទៅណាមកណាអស់ទៅ មិនបានស្រាវជ្រាវមើលអីផង ។

វណ្ណៈៈ ចឹងមីងកាលសម័យរដ្ឋប្រហារហើយឆ្នាំ១៩៧០មីងនៅក្នុងផ្ទះឬមីងចេញទៅធ្វើចលនាបដិវត្ត?

យឿនៈ ខ្ញុំនៅផ្ទះ ។

វណ្ណៈៈ ចឹងឆ្នាំណាបានមីងចេញមកចលនា?

យឿនៈ ចេញមកព្រៃហ្នឹងកាលនៅភូមិនៅផ្ទះ កាលខ្ញុំចេញឆ្នាំ១៩៧២ ចុង៧១ដើម៧២ ។

វណ្ណៈៈ ចឹងកាលមីងចូលឆ្នាំ៧២ហ្នឹង មីងចូលដំបូងមីងចូលនៅកន្លែងណា?

យឿនៈ ចេញទៅខាងអង្គរបុរីហើយទៅខាងលើទៀតទៅទៅខាងតាអាំនោះណាស់ ខេត្តកំពង់ស្ពឺនោះ ។

វណ្ណៈៈ ចឹងមានព្រៃតាអាំទៀត?

យឿនៈ ចឹងហ្នឹងមិនធម្មតាទេ សម័យណាដូចសម័យណា ។

វណ្ណៈ: ចឹងកាលដែលមីងចេញទៅហ្នឹង តើមីងមានចិត្តចង់ទៅមានអ្នកមកអូសទាញឬមានគេមកបង្ខំទេ?

យឿនៈ អត់មានពីណាមកបង្ខំទេ ។

វណ្ណៈ: ចឹងយើងមានស្មារតីចង់ទៅ?

យឿនៈ កាលហ្នឹងតាមគ្នីគ្នាណា ក្នុងស្រុកភូមិគេទៅយើងក៏ទៅជាមួយគេដែរ តែម្ដាយនៅផ្ទះគាត់មិនចង់ឲ្យទៅទេ តែតាមគ្នីគ្នាចលនាចេញទាំងភូមិៗចឹងទៅ ។

វណ្ណៈ: ចឹងកាលមីងមានបានស្ដាប់ការប្រកាសរបស់សម្ដេចថាឲ្យកូនចៅចូលព្រៃម៉ាគីពេលហ្នឹង?

យឿនៈ ចាស ។

វណ្ណៈ: ចឹងមីងគិតថាចូលទៅតាមសម្ដេចដើម្បីរំដោះជាតិវិញ?

យឿនៈ ចាស ។

វណ្ណៈ: ចឹងឪពុកម្ដាយមីងចង់ឃាត់មីងមិនឲ្យទៅទេ ព្រោះមីងជាស្រ្ដីមិនចង់ឲ្យកូនទៅចឹងៗ?

យឿនៈ ម្ដាយឃាត់ដែលថាមិនឲ្យទៅទេ ចុះធម្មតាមានពីណាអ្នកធ្វើអ្នករកចិញ្ចឹមគាត់ ម៉ែខ្ញុំមេម៉ាយផង ហើយពេលហ្នឹងអាយុ១៨ឆ្នាំ កាលហ្នឹងសុំគាត់ដែលថា ម៉ែកូនសុំទៅព្រៃជាមួយគេ គាត់ថាកូនអើយកូនមិនដែលឃ្លាតពីម៉ែចឹង បើកូនឯងទៅតែ១០ថ្ងៃបានហើយ ឲ្យទៅខោអាវមួយចង្កេះ មិនឲ្យយកអីមកទេ ក្រមាមួយខោអាវមួយចង្កេះ បានបងជីដូនមួយចូលទៅយកវិញចេញពេលយប់ ។

វណ្ណៈ: ចឹងកាលហ្នឹងទៅជាមួយបងជីដូនមួយឈ្មោះអីដែរ?

យឿនៈ ឈ្មោះ សេង សុភិន នៅភូមិជាមួយគ្នាស្លាប់បាត់ហើយ ។

វណ្ណៈ: ចឹងកាលទៅជាមួយមីងហ្នឹងមានគ្នាច្រើនដែរ?

យឿនៈ ទៅច្រើនណានារីៗទាំងភូមិហ្នឹងជាង១០នាក់ទៅណាស់ ហើយបងៗគេធ្វើឈ្លបមុនទៅណាស់ ។

វណ្ណៈ: ចឹងមានបងៗរបស់មីងចូលធ្វើឈ្លបមុន?

យឿនៈ ហ្នឹងហើយ បងជីដូនមួយក្នុងភូមិហ្នឹង ចូលទៅយកចេញពីភូមិហ្នឹងទៅខាងអង្គរបុរីហើយបានទៅលើទៀត ។

វណ្ណៈ: ចឹងបងប្អូនមីងបង្កើតបានចូលចលនាបដិវត្តហ្នឹងមានប៉ុន្មាននាក់ដែរ?

យឿនៈ ចូលពីរនាក់ទេ ។

វណ្ណៈ: ចូលមីងមួយ?

យឿនៈ ចូលបងប្រុសមួយទៀតតែស្លាប់បាត់ ។

វណ្ណៈ: គាត់ស្លាប់នៅពេលណា?

យឿនៈ ស្លាប់កាលនៅកំពង់សោម នៅស៊ីងហាវ ។

វណ្ណៈ គាត់ឈ្មោះ អីទៅ?

យឿនៈ ឈ្មោះ សុខ សារឿន ។

វណ្ណៈ មីងមានដឹងថាហេតុអីបានជាគាត់ស្លាប់?

យឿនៈ ស្លាប់ដោយសារដឹកជញ្ជូនកម្លាំងឆ្លងទឹកពេលរត់ហ្នឹង ។

វណ្ណៈ ចឹងស្លាប់ក្រោយឆ្នាំ១៩៧៩ទេ?

យឿនៈ ចាស!ចប់នេះហើយណា កាលហ្នឹងគាត់ចម្លងកម្លាំង ព្រោះគាត់ជាមេទ័ពនៅកន្លែងហ្នឹង ។

វណ្ណៈ ចឹងគាត់ធ្វើអំដែរ?

យឿនៈ ចាស!កងពល គាត់ពូកែខាងទឹកដែរ ពូកែទៅពូកែមកងាប់ តាមមើលគាត់រម្មូលក្រពើវាត្រជាក់ពេក បើមួយថ្ងៃវាល់ល្ងាចដឹកជញ្ជូន ឆ្លងទូកឬហែលក្បូនយ៉ាងម៉េចទេ ខ្ញុំមិនដឹងដែលខ្ញុំនៅនេះកាលហ្នឹង ។

វណ្ណៈ ចឹងឮគាមគេទេ?

យឿនៈ ឮគាមគេនៅហ្នឹង គេប្រាប់មក ។

វណ្ណៈ ចឹងកាលមីងចេញទៅមន្ទីរតាអាំហ្នឹង តើតាអាំប្រធានឬមួយយ៉ាងម៉េច?

យឿនៈ មិនមែនទេ គេហៅភូមិតាអាំតែម្តង កាលសម័យខ្មែរក្រហមគេហៅមន្ទីរ២០៨ជាមន្ទីរអ្នកទោស តែពួកខ្ញុំមិនមែនអ្នកទោសទេ ខាងនារីរាប់រយនាក់ តែខាងអ្នកទោសនោះគេនៅមន្ទីរតាអាំហ្នឹងវាផ្សេងម្ខាងម្នាក់គេហៅមន្ទីរ២០៨នៅមុំហ្នឹង ភូមិតាអាំនៅជិតភូមិផុង ។

វណ្ណៈ ចឹងកាលមីងនៅឆ្នាំ១៩៧២ហ្នឹង យ៉ាងម៉េចបានជាមានអ្នកទោសអីចឹង?

យឿនៈ មាន ។

វណ្ណៈ ចឹងអ្នកទោសមានតាំងពីពេលហ្នឹងមក?

យឿនៈ មានតាំងពីហ្នឹងមក ក្រោយមកគេយកមកដាក់ហ្នឹង គេយកអ្នកទោសដាក់នៅមន្ទីរតាអាំហ្នឹងតែពេលហ្នឹងខ្ញុំចេញមកធ្វើទ័ពហើយ ។

វណ្ណៈ កាលហ្នឹងគេឲ្យមីងធ្វើអីទៅ?

យឿនៈ អត់ធ្វើអីកាប់ឈើកាប់ព្រៃធ្វើកន្លែងជ្រកកោន ប្រូតស្បូវក្រងស្បូវចឹងទៅ ។

វណ្ណៈ ចឹងកាលមីងនៅដំបូងហ្នឹងគេឲ្យមីងនៅជញ្ជូនស្បៀងឬគេឲ្យមីងកាន់កាំភ្លើង?

យឿនៈ អត់ទេ ពេលចេញពីហ្នឹងមកគេឲ្យហាត់រៀន គេឲ្យកាន់កាំភ្លើង ។

វណ្ណៈ ចឹងរាល់ថ្ងៃហ្នឹងមីងចេះបាញ់ទេ?

យឿនៈ អត់មានល្បង់ទេ ។

វណ្ណៈ៖ ចឹងមីងធ្លាប់កាន់កាំភ្លើងបេទេ?

យឿនៈ បេក៏ខ្ញុំធ្លាប់ កាន់បង់ត្រឡោកកាន់សារ៉ាន់ធីណាយ យើងនេះអា៧៩ អីហ្នឹងខ្ញុំចេះទាំងអស់បេ៤០ បាញ់បាន៥គ្រាប់ ។

វណ្ណៈ៖ ចឹងគេថាស្រីៗបាញ់កាំភ្លើងបេបានច្រើនជាងប្រុសៗ ?

យឿនៈ បាញ់បានច្រើនជាងប្រុស ព្រោះស្រីមានជាតិត្រជាក់ជាងប្រុស ស្រីៗបាញ់បាន៦គ្រាប់ពួកខ្ញុំវេទនាណាស់ ធ្វើម៉េចបើសម័យចឹងទៅហើយ ការងារដូចប្រុស ។

វណ្ណៈ៖ ចឹងកាលនៅហ្នឹងគេហៅតំបន់ប៉ុន្មានដែរ ខាងកំពង់ស្ពឺហ្នឹង?

យឿនៈ មិនដឹងជាតំបន់ប៉ុន្មានទេ ។

វណ្ណៈ៖ ហើយកាលហ្នឹងប្រធានមីងឈ្មោះអីដែរ?

យឿនៈ ប្រធានមានយាយ ខាង តា ភាព ហើយយាយ បូ ស្លាប់បាត់អស់ហើយ ។

វណ្ណៈ៖ ចឹងយាយខា យាយ បូ គាត់ប្រធានអីដែរ?

យឿនៈ គាត់ជាប្រធានមន្ទីរហ្នឹងតែម្ដង ។

វណ្ណៈ៖ កាលហ្នឹងមន្ទីរលេខប៉ុន្មាន?

យឿនៈ មន្ទីរ១៥០ ។

វណ្ណៈ៖ កាលហ្នឹងមានកងពលហើយនៅ?

យឿនៈ អត់ទេ ។

វណ្ណៈ៖ ចឹងឆ្នាំណាដែលមីងបានចេញមកខាងទ័ពតែម្ដង?

យឿនៈ នៅឆ្នាំ១៩៧៣ បានចេញមកហាត់បីខែនៅមន្ទីរតា ខែម ហ្នឹងគេរើសចូលកងទ័ព ។

វណ្ណៈ៖ មន្ទីរតា ខែម ហ្នឹងមានលេខទេ?

យឿនៈ គេហៅមន្ទីរអីទេ ភ្លេចអស់ហើយ ។

វណ្ណៈ៖ ចឹងហាត់បីខែហើយគេឲ្យមីងធ្វើអីទៀត?

យឿនៈ ចេញមកសមរភូមិតែម្ដង ។

វណ្ណៈ៖ ចេញមកសមរភូមិខាងណាវិញ?

យឿនៈ កាលហ្នឹងចេញមកខាងតាកែវជិតស្រុកភូមិខ្លួនឯងវិញ តាកែវចឹងទៅ ភ្នំដិនចឹងទៅបានបែកទៅបានមកភ្នំពេញអីហ្នឹង កាលតាកែវ សំរោងយោង ជិតស្វាយចេកអី វាយខាងជាំស្វាអីហ្នឹង ។

វណ្ណៈ៖ ចឹងកាលឆ្នាំ៧៣មានកងពលមានវរៈហើយនៅមីង?

យឿនៈ មានវរៈមានកងវរៈហើយ ។

វណ្ណៈ៖ ចឹងកងពលលេខប៉ុន្មាន?

យឿនៈ កាលហ្នឹងកងពលលេខប៉ុន្មានទេ តា សុច  តា សឿន ហ្នឹង ស្ដាប់អស់ហើយតាមមើល ។

វណ្ណៈ  ចឹងប្រធានកងពលឈ្មោះ សុច ឈ្មោះ សឿន?

យឿនៈ ហ្នឹងហើយ ។

វណ្ណៈ  ចឹងមីងអត់ដឹងថាកងពលលេខប៉ុន្មានទេ?

យឿនៈ មើលកាលហ្នឹងកងពលទី៣ ។

វណ្ណៈ  ហ្នឹងសុទ្ធតែវាយចូលភ្នំពេញដែរ?

យឿនៈ ចូលភ្នំពេញ ហើយវាយតាមខេត្តតូចៗណា ។

វណ្ណៈ  កាលដែលវាយហ្នឹងមីងមានភ័យខ្លាចទេ?

យឿនៈ ធម្មតា  កាលយើងហាត់ហ្នឹងគេពិសោធន៍ឲ្យយើងដឹងហើយ  គេវាយបន្ទាលួសហើយគេឲ្យលូនអី ចឹងវាមានពិសោធន៍ច្រើនដែលហើយ  តែយើងអនុវត្តជាក់ស្ដែងមិនបានធ្វើដូចហាត់ទេ  ធ្វើដូចហាត់គើមៗហ្នឹងងាប់ឥឡូវ ។

វណ្ណៈ  ចឹងយើងវាយជាក់ស្ដែងយើងធ្វើយ៉ាងម៉េចទៅ?

យឿនៈ យើងវាយចល័តជាក់ស្ដែង ។

វណ្ណៈ  ចឹងតាមមើលទៅកម្លាំងខ្មែរក្រហមនិងកម្លាំងខាង លន់ នល់ ហ្នឹងមានស្លាប់ដូចគ្នា?

យឿនៈ ស្លាប់ដូចតែគ្នា កាលសម័យនោះវាម្យ៉ាងសម័យ ប៉ុល ពត ប្រើកម្លាំងអត់អស់លុយងាប់១០ នាក់ចូល២០ទៀត  កម្លាំងច្រើនណាស់ចូល  អត់មានថារៀលថយហើយមិនបាច់ចាប់  ដូចថាប្រជាជនគាត់ជម្រុញកូនគាត់ឲ្យទៅ ។

វណ្ណៈ  ចឹងហើយបានជាសង្គ្រាមខ្មែរក្រហម៥ឆ្នាំហ្នឹងលឿនដោយសារមានទឹកចិត្ត?

យឿនៈ ចាស! ពេលវាយទីតាំងមួយៗទៅតាមខ្សែត្រៀមរបួសឬស្លាប់អីចឹងមានអ្នកចាំសែងនៅទីស្នាក់ការហូតហើយមានរបស់ឲ្យយើងហូបទៀតអត់មានខ្វះចឹងបានខ្ញុំថា    អត់មានលុយមានកាក់តែប្រើកម្លាំងខ្លាំង ។

វណ្ណៈ  ចឹងកាលហ្នឹងមានទម្លាក់គ្រាប់បែកមីងភ័យទេកាលហ្នឹង?

យឿនៈ ទម្លាក់គ្រាប់បែកភ័យចេះតែភ័យហើយតែមិនដឹងជាធ្វើយ៉ាងម៉េច       បើកំពង់តែប្រយុទ្ធក្នាយន្តហោះពីលើផងពីក្រោមផង  យើងដឹងស្នូរខុសាហរណ៍ថា  គ្រាប់វត់ទៀបឬខ្ពស់យើងសុខចិត្តដើរឲ្យត្រូវចុះជើង  កុំឲ្យតែត្រូវក្បាល  បើខ្ពស់យើងអោន  បើត្រូវក្បាលឆាប់ខូចដៃជើងសរសៃប្រាសាទ  យូរទៅមានខ្លាចអី  ដូនកាលមានខ្លាចអីមួយគ្រង់សេធ្លាក់មកងាប់បួនទៅប្រាំនាក់នៅតែខ្ញុំក៏មានដែរ  ធម្មតាទេ  បែរមុខទល់គ្នា  រឿងប្រយុទ្ធគ្នា  ដូនកាលគ្រាប់មកចំខ្ទិចសាច់សល់តែមួយចាន  តែថាយើងស្ម័គ្រធ្វើទៅហើយស្លាប់ចោលទៅ  រស់យកទៅ ។

វណ្ណៈ  កាលហ្នឹងគេឲ្យមីងមានឋានៈអីដែរ?

យឿនៈ គេមានឲ្យធ្វើអីទេ ឲ្យធ្វើត្រឹមក្រុម ក្រោយមកប្រធានកងតូច ។

វណ្ណៈ  ប្រធានអនុសេនាតូច?

យឿនៈ ចាស ។

វណ្ណៈ  អនុសេនាតូចមានគ្នាប៉ុន្មាននាក់?

យឿនៈ មានគ្នា៣៥នាក់ហ្នឹង អនុសេនាធំមាន១២០នាក់ មួយវរសេនាតូចវាមាន៣០០នាក់ ដល់កង ពលមាន៤០០ទៅ៥០០ចឹងទៅដល់រាប់ពាន់នាក់ ។

វណ្ណៈ  បាទ ។

យឿនៈ កាលសម័យនោះមានការតឹងតែងដែរ បើយើងកសាងខ្លួនទាន់ បើយើងជាប់និន្នាការមានបង ប្អូនរៀនខ្ពស់ កាលណាចូលថ្នាក់ទី៧ហើយ យើងមានការភ័យព្រួយ ឲ្យតែរៀនបានថ្នាក់ទី៧ ឡើងគេថាយើងរៀនបានខ្ពស់ ជាបញ្ញាជន មានគេស្រាវជ្រាវប្រវត្តិរូបដល់ផ្ទះ ចឹងបានថា សម័យនេះរកតែអ្នកចេះ ហើយសម័យនោះយ៉ាងម៉េចបានជាសម្លាប់គ្នាចោល មកពីយើងល្ងង់ បានគេស្រួលប្រើតាមមើល ។

វណ្ណៈ  មីងគិតចឹង?

យឿនៈ ចាស!ខ្ញុំគិកចឹងដូចគ្នា ។

វណ្ណៈ  ចឹងបើយើងចេះគេពិបាកប្រើយើង?

យឿនៈ ហ្នឹងហើយ ។

វណ្ណៈ  ចឹងប្រហែលជាថ្នាក់ដឹកនាំខ្មែរក្រហមគាត់គិតចឹងតាមមីងយល់?

យឿនៈ គិតចឹងដូចគ្នា មិនដឹងជាធ្វើយ៉ាងម៉េចបើសម័យវាចឹងហើយតាមយុគសម័យមួយៗវាមើលមិន ឃើញ ។

វណ្ណៈ  ចឹងកាលហ្នឹងមុខព្រួញរបស់មីងហ្នឹងវាយចូលតាមច្រកណាបានចូលដល់ភ្នំពេញ?

យឿនៈ ខ្ញុំកាលឆ្នាំ៧២-៧៣រហូតដល់៧៤ ខ្ញុំចេញពីតាកែវទៅ គេផ្លាស់ខ្ញុំឲ្យទៅភ្នំដិនទៅវាយជាមួយ វៀតណាម ។

វណ្ណៈ  ឆ្នាំ៧៤មិនទាន់ឈ្នះភ្នំពេញផងហ្នឹង?

យឿនៈ មិនទាន់ឈ្នះភ្នំពេញទេ ភ្នំពេញគេនៅហ៊ុំព័ទ្ធតាកែវគេនៅហ៊ុំព័ទ្ធដែរ ខ្ញុំទៅនៅខាងភ្នំដិននោះវាយ ទៅសំបុកមាន់អីនោះ ។

វណ្ណៈ  ចឹងកាលឆ្នាំ៧១-៧២ហ្នឹងមានសហការជាមួយវៀតណាមវាយជាមួយទាហាន លន់ នល់ទេ?

យឿនៈ មាន ។

វណ្ណៈ ចឹងហេតុអីបានជាឆ្នាំ៧៨វាយជាមួយវៀតណាមវិញ?

យឿនៈ អាហ្នឹងមិនដឹងជាយ៉ាងម៉េច បើកាលហ្នឹងគេយកពួកខ្ញុំទាំងនារីទាំងបុរសហ្នឹងនៅភ្នំដិនណាស់ ស្រួប្រេងយកទៅលក់ឲ្យយួនដែរ បេះក្រូចយកទៅលក់ឲ្យយួនដែរ នៅស្រុកគីរីវង្សហ្នឹង ដឹងយ៉ាងម៉េចបានជាយកកម្លាំងទៅវាយនៅសំបុកយួននោះ ខ្ញុំក៏វាមិនយល់ដែលហ្នឹងណាស់ ព្រោះយើងតូចតាចដែលក្តាប់រឿងនយោបាយវាមិនជ្រៅទេ ។

វណ្ណៈ ចឹងថ្នាក់លើបញ្ជាទៅណាយើងទៅហ្នឹង?

យឿនៈ ចាស ។

វណ្ណៈ ចឹងមីងឆ្នាំ៧៥អត់បានចូលដល់ក្នុងទីក្រុងភ្នំពេញទេ?

យឿនៈ ឆ្នាំ៧៥ខ្ញុំទៅដល់ ដល់ជ័យជម្នះភ្នំពេញ គេថាភ្នំពេញវាយបែកហើយគេទៅយកពួកខ្ញុំពីភ្នំដិនហ្នឹងមក ។

វណ្ណៈ ចឹងប្រជាជនជម្លៀសចេញអស់ហើយបានមីងចូលដល់ភ្នំពេញ?

យឿនៈ ចាស ។

វណ្ណៈ ចឹងមីងអត់បានឃើញប្រជាជនគេជម្លៀសចេញយ៉ាងម៉េចទេ?

យឿនៈ អត់ទេ ឃើញនៅមានមួយពីរដែលគាត់នៅផ្ទះគាត់ កាលហ្នឹងគេយកពួកខ្ញុំពីភ្នំដិនមកគេថាភ្នំពេញមានជ័យជម្នះហើយ ។

វណ្ណៈ ចឹងមានន័យថា ខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងហើយបានគេបញ្ជូនមីងមកភ្នំពេញ?

យឿនៈ ចាស ។

វណ្ណៈ ចឹងមកទាំងវរៈនិងកងពលតែម្តង?

យឿនៈ មកទាំងអស់ ។

វណ្ណៈ មកជួបជុំគ្នានៅថ្ងៃទីប៉ុន្មាន ថ្ងៃទី១៧មេសារំដោះប្រហែលជាប៉ុន្មានថ្ងៃក្រោយមក?

យឿនៈ ថ្ងៃ១៧មេសារំដោះហើយ ក្រោយប្រហែលជា១០ថ្ងៃកន្លះអីទៅ ពេលកម្លាំងមកជុំគ្នាហើយគេបានរៀបចំកម្លាំងបែងចែកគ្នា ខ្លះទៅនិរតីខ្លះទៅភ្នំពេញរៀនរាប់ខែចឹងទៅមេៗខ្លះបែកគ្នាទៅខាងខេត្តមណ្ឌលគីរី ខ្លះទៅរតនគីរីចឹងទៅណាស់ ហ្នឹងរៀបចំចឹង ខ្លះទៅខាងកំពង់សោមអត់មាននៅជុំគ្នាទេ គេរៀបចំទៅតាមមុខសញ្ញាមួយៗ មេៗគេមើលកម្លាំងណាត្រូវទៅណា កម្លាំងច្រើនដែលកាលហ្នឹង ។

វណ្ណៈ ចឹងមីងមានដឹងថាមានប៉ុន្មានកងពលចូលភ្នំពេញ?

យឿនៈ ខ្ញុំមិនបានដឹងទេ ។

វណ្ណៈ ចឹងមីងគ្រាន់តែដឹងថាកងពលទី៣របស់មីងចូលភ្នំពេញ?

យឿនៈ ចាស ។

វណ្ណៈ នៅពេលមីងចូលភ្នំពេញហើយ គេមានបែងចែកមីងទៅខាងណាទៀតទេឬមួយនៅភ្នំពេញរហូតដល់ឆ្នាំ១៩៧៩?

យឿនៈ អត់ទេ ក្នុងឆ្នាំ៧៥ហ្នឹងដែលដូចថានៅក្នុងភ្នំពេញ បានប្រហែលជាមួយខែកន្លះចឹងគេបញ្ជូនទៅខេត្តរតនគីរីនោះ កាលហ្នឹងឆ្លងទៅភូមិភាគពិសេសតាមដំណាក់ចឹងទៅ ។

វណ្ណៈ ចឹងកាលហ្នឹងទៅជាយោធាដដែលឬទៅជាលក្ខណៈជាពេទ្យជាអី?

យឿនៈ ជាយោធាដដែល ទៅដល់ហ្នឹងឈប់ហើយ ។

វណ្ណៈ កាលហ្នឹងទៅការពារព្រំដែន?

យឿនៈ ចាស!កាលការពារព្រំដែន តែកាលហ្នឹងក៏ធ្វើស្រែដែរ ដាំដំឡូងអីចឹងទៅ កម្លាំងយុវជនទៅខាងមុខទៅ ។

វណ្ណៈ ចឹងនៅខាងរតនគីរីហ្នឹងប្រធានកងពលពីណាគេ?

យឿនៈ តាសារឿន ០៥និង០៦នៅជិតគ្នាទាំងអស់ ។

វណ្ណៈ តា០៦នៅខាងមណ្ឌលគិរីទេ?

យឿនៈ ដល់ហើយបានគាត់ទៅខេត្តមណ្ឌលគិរី ក្រោយមកបានគេបែកគ្នាមុននៅជុំគ្នា ក្រោយមកតា០៦ទៅមណ្ឌលគិរី តា០៥នៅវឹនសៃ ខេត្តរតនគិរី ពួកគាត់ស្លាប់អស់ហើយ ។

វណ្ណៈ ចឹងកាលហ្នឹងនៅក្នុងកងពលលេខប៉ុន្មាន កងពលនៅរតនគីរីឆ្នាំ៧៥មកមានការផ្លាស់ប្តូរកងពលមានកងពល៩២០មាន?

យឿនៈ កងពល៩២០ តាសាន ខ្ញុំនៅកងពល៨០១ ខេត្តរតនគីរី ។

វណ្ណៈ ចឹងកាលមីងនៅខេត្តរតនគីរីហ្នឹងមិនសូវលំបាកទេ ការហូបចុកគ្រប់គ្រាន់ទេ ហើយមានជំងឺឈឺចាញ់ដែលឬមួយយ៉ាងណា មានឈឺស្លាប់ដែលកងទ័ពនៅហ្នឹង?

យឿនៈ មានចាញ់ ខ្ញុំអីឈឺសន្លំ៧យប់៧ថ្ងៃបានដឹងខ្លួន កម្លាំងស្លាប់អស់មិនចេះតិចទេ ទៅដំបូងគ្រុនចាញ់អស់១៨៥នាក់នោះ នៅមួយមន្ទីរពេទ្យ ស្លាប់និងចាញ់មើលមិនជា ខ្ញុំថាតែមិនរស់ផងទេ កាលទៅដល់ដំបូងចាញ់ណាស់ មូលហេតុដែល៩២០ចេញពីវឹនសៃដោយសារចាញ់ច្រើនពេក ក៏ដូរគ្នាទៅមណ្ឌលគិរីទៅចាញលច្រើនពេក ។

វណ្ណៈ ចឹងចេះតែមានស្លាប់ជាបន្តបន្ទាប់ចឹងទៅ?

យឿនៈ ចាស ។

វណ្ណៈ ចឹងនៅខាងរតនគីរីហ្នឹងគេហៅថាស្រុកអីគេ?

យឿនៈ ស្រុកវឹនសៃ ។

វណ្ណៈ៖ នៅហ្នឹងគេហៅតំបន់ប៉ុន្មានដែរ?

យឿនៈ ភ្លេចបាត់ហើយតំបន់ហ្នឹងដូចជាតំបន់ប៉ុន្មានទេ ។

វណ្ណៈ៖ ចឹងអនុតា សារឿន មានពីណាគេ?

យឿនៈ អនុ មាន តាស៊ុង តាញ៉ាន់ ក្រោយទេ ដល់ចេញមកនេះបានជួបគ្នាជាមួយ តាញ៉ាន់ ពីមុន មាន០៥ មានតាស៊ុង មានអីទេ កាលហ្នឹងមានបីតែគេដកតា សានទៅនេះទៅ ។

វណ្ណៈ៖ ចឹងឈ្មោះ ស៊ុង ហ្នឹងដល់ក្រោយមកមានគេចាប់ខ្លួនដែរ?

យឿនៈ ហ្នឹងហើយគេចាប់ខ្លួន គេថាប្រឆាំងអាហ្នឹងនៅកាលនៅវីនសៃទេណាស់ មកដល់ថាឡាបរិវ៉ាត់ បានគេប្រាប់ មកដល់សាលាថាឡាបរិវ៉ាត់ស៊ីងត្រែងហ្នឹង ។

វណ្ណៈ៖ ចឹងកាលហ្នឹងមីងគិតថា គាត់មានចិត្តក្បត់អង្គការមែនឬមួយយ៉ាងម៉េច?

យឿនៈ អាហ្នឹងរឿងផ្ទៃក្នុងយើងក្តាប់វាមិនបានដែរ រឿងគេមេយើងមិនបានដឹង ខ្ញុំវាមិនយល់ដែរ កាលនៅជាមួយគ្នានោះដូចជាធម្មតាចឹង ប៉ុនផ្នែកត្រង់នេះដែរ ផ្នែកត្រង់សភាពការណ៍ច្របូកច្របល់នៅវីនសៃហ្នឹង គាត់ថា ពួកនេះសុំថតរូមគ្នាមួយមកចឹងណាស់ តាស៊ុង ពេលគេជប់លាងហ្នឹង គាត់ថាមកសុំថតរូមគ្នាមួយមកទុកជាអនុស្សាវរីយ៍យើងធ្លាប់ស្គាល់ ។

វណ្ណៈ៖ ចឹងកាលហ្នឹងទោះបីយើងខំធ្វើការឲ្យអង្គការមែនតែយើងនៅមានការភ័យខ្លាចដូចតែគ្នា?

យឿនៈ ខ្លាចដូចតែគ្នា ។

វណ្ណៈ៖ មានបាត់ខ្លួនច្រើនទេ នៅពេលហ្នឹង?

យឿនៈ អ្នកដែលធ្វើខុសគេអត់មានយកទៅណាទេ គេយកទៅដាក់មួយកន្លែងនៅបឹងកន្សែងនោះ គេយកទៅដាក់ហ្នឹង ខ្ញុំមនុស្សខ្ញុំមិនសូវជានេះប៉ុន្មានទេ ខ្ញុំសម័យសង្គ្រាមខ្ញុំធ្លាប់ក្តោគគុកដល់មកជាប់ពេលចឹង ពេលជិះឡានមកពីបកែវអី ឃើញគេដាក់ចង្វាក់គ្នាគេឲ្យចេញមកជម្រះស្មៅក្បែរថ្នល់ ខ្ញុំបោះខ្នុរក្រូចខ្ញុំបោះឲ្យហូប ខ្ញុំស្គាល់ៗ កាលហ្នឹងខ្ញុំជិះឡានមក កាលហ្នឹងគេឲ្យខ្ញុំជិះក្នុងកាប៊ីនខ្ញុំអត់ជិះខ្ញុំជិះលើ មកឃើញគេឲ្យជម្រះស្មៅក្បែរផ្លូវចឹង ខ្ញុំបោះខ្នុរ ក្រូចពោធិសាត់ឲ្យអ្នកដែលស្គាល់ៗហ្នឹង ។

វណ្ណៈ៖ ធ្លាប់ធ្វើយោធាជាមួយគ្នា?

យឿនៈ ចាស!ធ្លាប់ធ្វើយោធាជាមួយគ្នា គេថាយ៉ាងម៉េចបានជាឲ្យអ្នកទោស ខ្ញុំថាអ្នកទោសស្អី កាលពីសង្គ្រាមធ្វើការជាមួយគ្នាផ្តួផ្តាច់ សម័យឥឡូវយកគ្នាមកចឹងគ្នាធ្វើខុសបន្តិចស៊ីដំឡូងបន្តិចបន្តួចយកគ្នាមកដាក់ដែលមិនចេះអាណិតគ្នាទេ ខ្មែរដូចតែគ្នា ។

វណ្ណៈ៖ ចឹងមីងមិនខ្លាចគេចាប់មីងទេ?

យឿនៈ ខ្ញុំមិនខ្លាចទេ ខ្ញុំថាទៅយកខ្ញុំទៅដាក់ហ្នឹងដែលទៅ ខ្ញុំមិនដែលខ្លាចខ្ញុំពូកែខាងតវ៉ា គេថាវាអាង មានខ្នង មេធំៗហ្នឹងគាំទ្រវាណាស់ ចុះកាលពីសង្គ្រាមហ្នឹងវាជាមួយតែគ្នា គ្នាខុសបន្តិចបន្តួច យកមកធ្វើចឹង ។

វណ្ណៈ ចឹងកាលមីងនៅខាងវីនសែអីហ្នឹងគេមានឲ្យតួនាទីមីងទៀតទេ?

យឿនៈ ខ្ញុំមិនចង់ធ្វើអីទេ ធ្វើធំជាងហ្នឹងទៀតទៅយើងជាប់និន្នាការមានបងប្អូនចឹង ។

វណ្ណៈ ចឹងនៅត្រឹមប្រធានវរៈអនុសេនាតូចដដែល?

យឿនៈ ប្រធានវរៈអនុសេនាតូច ដល់ពេលចប់មកចឹងបានគេឲ្យមកទទួលខុសត្រូវមន្ទីរអីចឹងណាស់ មន្ទីរ កងពលមីងៗនៅក្រោយហ្នឹង ។

វណ្ណៈ ចឹងមីងយល់ថា របបខ្មែរក្រហមធ្វើបាបតែគ្នាឯងចឹងទៅធ្វើឲ្យការកាន់អំណាចគាត់បានឆាប់ឬ មានមូលហេតុអីផ្សេងទៀតបើតាមមីងយល់?

យឿនៈ តាមខ្ញុំយល់ខ្មែរក្រហមឆាប់បរាជ័យចឹង មកពីប្រើកម្លាំងគ្មានលុយកាក់ មានរបបខុសទាហរណ៍ ម្យ៉ាងម្នាក់ ដូចថាប្តីទៅមុខប្អូនប្រុសទៅមុខចឹងកូនចៅនៅក្រោយរបបគេបើកឲ្យចឹងទៅខោអាវ ស្បៀកពាក់របបហូបចុកគេបើកឲ្យចឹង វាស្រួលម្យ៉ាងចឹងទោះបីយើងឈឺមានពេទ្យមានថ្នាំពេទ្យ គេធានាមើលទាំងអស់អត់មានអស់លុយករកគ្រោះថ្នាក់ណាស់ ក្រោយមក ។

វណ្ណៈ ចឹងទី២ទៀតអាចថាសម្លាប់គ្នាឯងចោល?

យឿនៈ ចាស ។

វណ្ណៈ ធ្វើឲ្យយុវជនទាំងអស់បាក់ទឹកចិត្ត?

យឿនៈ ម្យ៉ាងទៀតដណ្តើមអំណាចគ្នា យើងគិតឲ្យវែងឆ្ងាយចង់ធ្វើធំអាមួយចង់ធ្វើអធិរាជ្យស្តេចក្រាញ់ តែឯងចឹងទៅ ដល់ទៅទំនាស់គ្នាបែកបាក់សាមគ្គីហើយណា ។

វណ្ណៈ ចឹងតាំងពីមីងចូលបដិវត្តហើយមីងមានដែលសុំអង្គការទៅលេងផ្ទះទេ?

យឿនៈ អត់ទេ អត់មានទេ មិនដែលសុំទេ ។

វណ្ណៈ បើសុំដឹងថាអត់បានដែរ?

យឿនៈ សុំអត់បាន ទាល់តែមានការអនុញ្ញាតគេអនុគ្រោះ គេឲ្យទៅដែលតែខ្ញុំមិនចង់មិនដឹងជាទៅរកអី ទៅឃើញឪពុកម្តាយវេទនា ធម្មតាយើងធ្លាប់មានកម្លាំងដាំដុះ ចិញ្ចឹមមាន់ទាយើងហូបសេរីបាន ឲ្យតែយើងធ្វើបាន ដល់ពេលសម័យនោះខ្ញុំដឹងដែរ ខ្ញុំទៅម្តងពីរដងដែលក្រោយពីខ្ញុំចេញមកមិន ដឹងជាធ្វើបាបយ៉ាងម៉េច ។

វណ្ណៈ ឆ្នាំណាមីងបានទៅលេងផ្ទះ?

យឿនៈ ខ្ញុំទៅចុងឆ្នាំ៧៣ ។

វណ្ណៈ  នៅតាំងពីសម័យមិនទាន់រំដោះភ្នំពេញផង?

យឿនៈ ចាស!តែការនោះនៅស្រុកហ្នឹងគេដាក់រួមហើយ បាយរួមតែកាលខ្ញុំទៅមិនខ្វះអីហូបទាំងអស់ ក្នុងភូមិហ្នឹងគេយល់ថា យ៉ាងម៉េចមិនដឹងទេ តែកាលហ្នឹងមិនខ្វះហូបទេ ដូចលោកនំចំណីគ្រប់មុខ រៀបឲ្យហូប ។

វណ្ណៈ  ចឹងកាលឆ្នាំ៧៣ទេ?

យឿនៈ ចាស ។

វណ្ណៈ  ចឹងឆ្នាំ៧៥ដល់៧៨មីងមានដែលបានទៅទេ?

យឿនៈ អត់ទេ ។

វណ្ណៈ  រហូតដល់ដាច់វៀតណាមចូល?

យឿនៈ ចាស ។

វណ្ណៈ  ចឹងពេលវៀតណាមចូលដល់ប្រទេសកម្ពុជាប្រទេសខ្មែរមុននិងវៀតណាមចូលហ្នឹងមានធ្វើសង្គ្រាមវាយជាមួយប្រទេសវៀតណាមទេ មុនបែកនៅខាងរតនគិរីហ្នឹង?

យឿនៈ មាន ។

វណ្ណៈ  ចឹងមានន័យថា ជុំវិញប្រទេសវៀតណាមវាយចូលគ្រប់ច្រកទាំងអស់?

យឿនៈ ចាស ។

វណ្ណៈ  ចឹងខាងរតនគិរីហ្នឹងក៏មានមុខសញ្ញាវាយចូលដែរ?

យឿនៈ វាយ ។

វណ្ណៈ  ចឹងពេលដែលវាយចូលចឹង មីងគិតថាស្រុកប្រែប្រួលហើយ តើមីងមានគំនិតថាចង់ទៅផ្ទះ មីងគិតយ៉ាងម៉េចដែលកាលពេលហ្នឹង?

យឿនៈ កាលនៅរតនគិរីហ្នឹង គេចល័តកម្លាំងឲ្យទៅខាងប៉ៃលិន ភ្នំកាង៉ុក បារាំងធ្លាក់ចឹងទៅណាស់ តាមព្រំដែនហ្នឹងរហូត ។

វណ្ណៈ  ចេញពីរតនគិរី?

យឿនៈ ចាស!ចេញពីខេត្តរតនគិរីហ្នឹងដើរឆ្លងពីថាឡាបរិវ៉ាត់ហ្នឹងតាមផ្លូវព្រំដែនហ្នឹងរហូត មកដល់បាក់អន្លង់ចឹងទៅណាស់ ចេញទៅលិចសៀវព្រំដែនហ្នឹងរហូត ទៅធ្លាយដល់ព្រៃមាន់ខាងស្រុកពួកនិយាយរួមខាងអូរល្ហុង អូរពេជ្រចិន្តា បារាំងធ្លាក់អី ។

វណ្ណៈ  ចឹងម៉ាផ្លូវហ្នឹងទាំងអស់?

យឿនៈ ម៉ាផ្លូវហ្នឹង ដើរចឹងស្ពាយអង្ករហូបតាមតែផ្លូវ ។

វណ្ណៈ  ចឹងមានស្លាប់តាមផ្លូវទេ?

យឿនៈ អត់មានទេ ។

វណ្ណៈ ចឹងមានមេដឹកនាំ?

យឿនៈ មានអ្នកដឹកនាំតាមផ្លូវ មានកម្លាំងតិចណាកម្លាំងមានរាប់រយរាប់ពាន់នាក់ ដើរទៅត្រូវជិះឡានក៏ជិះឡានខ្លះទៅ ដើរឆ្លងកាត់តាមដីថៃខ្លះដីខ្មែរខ្លះទៅ ដូចថាយើងទិញផ្លូវគេដើរ ។

វណ្ណៈ ចឹងមានទិញផ្លូវដើរទៀត?

យឿនៈ ចុះបើយើងចង្អៀតដូចម្ដុំកំរៀងព្រៃមាន់ គេបិតតឹងទិញដីគេដើរកាត់តាមដីថៃ ។

វណ្ណៈ ចឹងកាលហ្នឹងមានលុយមានអីដែរ?

យឿនៈ លុយយើងមានតើ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៩ហ្នឹងមីងដើរដល់ណាហើយយ៉ាងម៉េចបានជាមីងមកដល់ស្រុកអន្លង់វែង?

យឿនៈ កាលហ្នឹងចេះតែដើរជួបគ្នាចឹងទៅទាក់ទងគ្នារហូតដើរដល់៨០៨ រហូតដល់ត្រាងបារាំងធ្លាក់ ។

វណ្ណៈ ៨០៨ហ្នឹងនៅខាងណាវិញ?

យឿនៈ ៨០៨ហ្នឹង ។

វណ្ណៈ កម្លាំងប្រមូលផ្ដុំ?

យឿនៈ ប្រមូលពីលិចមកមិនដឹងអីមិនដឹង និយាយតាំងពីកោះកុងមកជុំគ្នា ។

វណ្ណៈ កាលហ្នឹងបើអ្នករត់ពីភ្នំពេញមកតាមផ្លូវមានស្លាប់ច្រើនណាស់ បើយើងមើលឯកសារឃើញមានច្រើនណាស់?

យឿនៈ ចាស!ពួកខ្ញុំនៅនេះមិនអីទេ បើពួកមកពីភ្នំពេញមានស្លាប់ច្រើន ហើយពួកខ្ញុំរើសកូនក្មេងយកមកចិញ្ចឹមច្រើនណាស់ ខ្លះប្ដីឈឺទៅលែងរួចហើយ ទៅចោលប្ដីទៅ កូនចោលតាមព្រៃចឹងទៅ បើខ្ញុំមានកម្លាំងប្រហែលជា៣០០នាក់ នាំគ្នាទៅស៊ីឈ្នួលកាច់ពោតឲ្យថៃដើម្បីយកលុយទិញអង្ករមកចិញ្ចឹមកម្លាំង កាលហ្នឹងកម្លាំងមាន៧០០ទៅ៨០០នាក់នៅជាមួយខ្ញុំ កម្លាំងនៅខាងក្រោយប្ដីនៅខាងមុខ ។

វណ្ណៈ ចឹងពេលមីងទៅដល់៨០៨មីងមានបានឃើញពីណាខ្លះនៅហ្នឹងមានឃើញតាម៉ុក នួន ជា ខៀវ សំផន នៅហ្នឹងទេ?

យឿនៈ អ្នកធំមិនបានជួបទេ ជួបត្រឹមកងពលជួប ដូចជា តាគេម អីហ្នឹង ។

វណ្ណៈ ចឹងមានជួប តាសារឿន តាសាន អីទេ?

យឿនៈ អត់ទេ អត់មានជួបទេ ព្រោះកម្លាំងហ្នឹងនៅកន្លែងឃ្លាំងអង្ករអីចឹងទៅណាស់ ។

វណ្ណៈ ចឹងតាម៉ុក គាត់ជាមនុស្សយ៉ាងម៉េចដែរ?

យឿនៈ តាម៉ុក គាត់ត្រចៀកស្រាល ពីណារាយការណ៍មុនឈ្មុះ តែចិត្តគាត់ល្អដែរ តា សុំលុយ១០០០ឬ៥០០មក លុយថៃ លុយដុល្លាណាគាត់ឲ្យភ្លាម ហើយនាឡិការសេរីស្អាត តា ឲ្យអាហ្នឹងមកខ្ញុំពាក់មើលម៉ោងម្តងខ្ញុំហត់ តា នោះដោះឲ្យភ្លាមយកទៅ យកទៅដើរចេញផុតទៅបើថានៅហ្នឹង អ្នកមកថា តា សុំ នាឡិការមួយគ្រឿងមក មោះ!ឯងពាក់យូរហើយឲ្យគេម្តងចឹងណាស់ បើយើងបានហើយដើរចេញទៅ លុយដកឲ្យទាំងខ្ទាស់ៗតែម្តង ។

វណ្ណៈ ចឹងបើសុំបានហើយមានគេមកសុំទៀតយកពីយើងឲ្យគេម្តងវិញ?

យឿនៈ ចាស!គាត់ចឹង ។

វណ្ណៈ ចឹងពេលមីងឈប់មានការផ្លាស់ផ្តូរតែម្តង មីងនៅឈរជើងនៅលើភ្នំដងរែកឬមួយនៅណា?

យឿនៈ ឈប់ពិតប្រាកដលែងទៅមុខយើងនៅព្រំដែនថៃ ។

វណ្ណៈ ព្រំដែនថៃមានច្រើនខ្លះនៅខាងម៉ាឡៃ?

យឿនៈ ហ្នឹងហើយខ្លះម៉ាឡៃខ្លះដូចខ្ញុំថានៅ៨០៨ខ្លះមក១០០១-១០០២-១០០៣ចឹងទៅណាស់ ។

វណ្ណៈ ចឹងមីងនៅចន្លោះណាប៉ុន្មានចំណុចហ្នឹង?

យឿនៈ ខ្ញុំកាលហ្នឹងចេញពី៨០៨មកមានគ្នាតែ១៥នាក់ទេ ចេញមកជាមួយមេៗដែលតែខ្ញុំមានគ្រួសារណាស់ គេឲ្យខ្ញុំទៅ១០០១វិញ ។

វណ្ណៈ ចឹងមីងនៅ១០០១?

យឿនៈ ចាស!ឡើងលើភ្នំដងរែកហើយហ្នឹង ។

វណ្ណៈ ចឹងនៅ១០០១ជាមួយប្តី?

យឿនៈ អត់ទេ ប្តីខ្ញុំទើបកសាងក្រោយដែរ កាលប្តីចាប់គូរឲ្យគ្មានសិទ្ធប្រកែកគ្មានមនោសញ្ចេតនាចឹងខ្ញុំយកអ្នកថ្មី ។

វណ្ណៈ មីងការឆ្នាំណា?

យឿនៈ គ្រួសារខ្ញុំគេនៅខាងទន្លេល្ពៅដែរ ឆ្នាំ១៩៨២ កាលការពីលើកមុននោះស្លាប់បាត់ហើយ ។

វណ្ណៈ ចឹងប្តីមុនស្លាប់ហើយ?

យឿនៈ ចាស!គេរៀបឲ្យនោះ ។

វណ្ណៈ ស្លាប់ដោយសារអីមីង?

យឿនៈ កាលហ្នឹងមិនត្រូវគ្នាទេ ប្រយុទ្ធគ្នាតាមផ្លូវហើយខ្ញុំមកមុនមក ។

វណ្ណៈ ចឹងពេលមានគ្រួសារហើយចឹងគេឲ្យមីងទៅសមរភូមិមុខទៀតដែលអត់?

យឿនៈ អត់ទេ មីងនៅក្រោយហើយនៅបង្កបង្កើនផលចឹងទៅ គ្រួសារខ្ញុំមុនធ្វើពេទ្យ ។

វណ្ណៈ ចឹងមីងការក្រោយនេះនៅឆ្នាំណា?

យឿនៈ ឆ្នាំ១៩៨២ ។

វណ្ណៈ ចឹងប្តីមុន?

យឿនៈ កាលហ្នឹងមិនជាឆ្នាំណាទេ សម័យខ្មែរក្រហមកាលហ្នឹងគេកសាងគ្រួសារចាប់ដៃគ្នាយកទាំងគូរៗកាលហ្នឹង?

វណ្ណៈ ការនៅរតនគីរី?

យឿនៈ ចាស!ការនៅរតនគីរីកាលហ្នឹង១៩គូ ។

វណ្ណៈ ចឹងកាលហ្នឹងជិតដាច់វៀតណាម?

យឿនៈ កាលហ្នឹងមិនទាន់ដាច់ទេ កាលហ្នឹងខ្ញុំមានអាយុ២៥ ខ្ញុំមិនចង់យកដងខ្ញុំប្រកែកយើងដងពេក៦ទៅ៧នាក់ហើយ គេគ្រប់គ្នាមានប្រកែកបានច្រើនចឹងណា ។

វណ្ណៈ ចឹងប្រហែលជាឆ្នាំ៧៧-៧៨?

យឿនៈ ប្រហែលជា៧៧ហ្នឹង កសាងបានមួយឆ្នាំបានយើងបែករំសាយទៅខ្ញុំមិនត្រូវគ្នាផងទេ អារឿងចាប់ជាគូៗចឹងមិនសូវត្រូវគ្នាភាគច្រើន ។

វណ្ណៈ ចឹងមីងការហើយមែនតែមិនសូវត្រូវគ្នាទេ?

យឿនៈ គេទៅមុខបាត់ទៅគេអត្តភាពគេ យើងអត្តភាពយើងចឹងទៅ ។

វណ្ណៈ ចឹងកាលហ្នឹងមីងមានកូនទេ?

យឿនៈ អត់មានកូនទេ មិនដែលបានរួមរក្សជាមួយគ្នាផង ខ្ញុំគេចរហូតខ្ញុំទៅសមរភូមិដែរ ខ្ញុំដឹងមកហើយដឹងថាមកបើកថ្នាំអីខ្ញុំនៅខ្សែត្រៀមនោះ ទៅរកទៅតាមត្រង់សេមួយណាក៏ជួយលាក់ការណ៍ រឿងវាចឹង ។

វណ្ណៈ ការមែនតែមិនបាននៅជាមួយគ្នាទេ?

យឿនៈ ចាស!ការហ្នឹងមិនបានការទេ ជប់លៀងណា ។

វណ្ណៈ ជប់លៀង១៩គូ?

យឿនៈ ចាស!កាលហ្នឹងកងពលមួយៗត្រូវយកយុទ្ធជនមករៀបការ តែគេសួរឲ្យយើងសម្រេចចិត្តដែរពីមួយអាទិត្យនៅ១០ចឹងទៅ គោរពតាមអត្តការអីចឹងទៅណាស់ រឿងសម័យនោះ ។

វណ្ណៈ ចឹងគ្រួសារមុនមីងនៅបែកគ្នារហូតទៅ ដល់ឆ្នាំ១៩៨២បានមីងការត្រឹមត្រូវ?

យឿនៈ ចាស!បែកគ្នាតែម្តង គាត់នៅមុខយើងនៅក្រោយ កាលហ្នឹងយួនមកដល់វីនសែខ្ញុំបែកទៅលិចចឹងទៅគាត់នៅមុខចឹងទៅ ។

វណ្ណៈ ចឹងក្រោយមកទៀតយើងវាយជាមួយទាហានរដ្ឋាភិបាលខាងខ្មែរក្រហមបានជំនួយពូខាងណាដែរ?

យឿនៈ កាលហ្នឹងជិនួយមកពីប្រទេសចិន តាំងពីកាំភ្លើងខោអាវទាំងអស់ហ្នឹង ។

វណ្ណៈ ចឹងពេលមីងការហើយ មីងនៅ១០០១មីងនៅកសាងក្រោយមីងលែងទៅខាងមុខហើយ?

យឿនៈ ចាស ។

វណ្ណៈ នៅខាងក្រោយគេធ្វើអីខ្លះទៅ?

យឿនៈ ខាងដឹកជញ្ជូន ។

វណ្ណៈ តែមីងមិនបានទៅមុខទេ ព្រោះមីងមានប្តីហើយ?

យឿនៈ មានប្តីហើយ ដូចយើងនៅលីវដែលហ្នឹងដឹកនាំកម្លាំងដឹកជញ្ជូនចឹង ជញ្ជូនគ្រាប់ជញ្ជូនស្បៀង យកទៅឲ្យសមរភូមិមុខ ។

វណ្ណៈ ចឹងទាល់មានកូនទើបគេឲ្យឈប់?

យឿនៈ ទាល់តែមានកូនមានចៅទើបគេរៀបចំឲ្យនៅមួយកន្លែងមីងៗណា ពេលនៅក្រោយគេឲ្យបិតចំរូងអីចឹងទៅណាស់ ។

វណ្ណៈ ចឹងកាលមីងនៅ១០០១ហ្នឹងកងពលលេខប៉ុន្មានទៅ?

យឿនៈ នៅកងពល៨០១ ។

វណ្ណៈ កងពល៨០១ពីណាដឹកនាំ?

យឿនៈ ក្រោយមកនៅ៨០២ មានតា ឆន កាល៨០១មាន តា ០៥ ក្រោយមកខ្ញុំនៅជាមួយតា ឆន កងពលធំ៨០១ តា សារឿនដដែលហ្នឹងហើយមានកងពលតូចតៗគ្នាមក ។

វណ្ណៈ ចឹងកាលធ្វើសង្គ្រាមជាមួយខ្មែរនិងខ្មែរជាមួយយណអីហ្នឹងមានស្លាប់រស់ធម្មតាទេ?

យឿនៈ មានស្លាប់រស់ធម្មតា អ្នកក្រោយធ្វើបុណ្យឲ្យទៅ ។

វណ្ណៈ ចឹងនៅឆ្នាំណាដែលគេចាប់ផ្តើមធ្វើចំរូង?

យឿនៈ ចំរូងកាលមកនៅ១០០១មុំបីហ្នឹង ។

វណ្ណៈ ប្រហែលជាឆ្នាំណា?

យឿនៈ តាំងពីឆ្នាំ១៩៨២-៨៣-៨៤ហ្នឹងមករហូតដល់៨៧-៨៨ក៏ធ្វើចំរូងដែរ ។

វណ្ណៈ ចឹងចំរូងមានតាំងពីឆ្នាំ៨០ជាងមករហូត?

យឿនៈ ចាស ។

វណ្ណៈ ចឹងចំរូងហ្នឹងគេយកស្អីទៅ?

យឿនៈ គេយកឫស្សី ។

វណ្ណៈ ឫស្សីហ្នឹងគេយកមកធ្វើយ៉ាងម៉េចដិបូង?

យឿនៈ យកមកពុះជ្រៀកវាប៉ុនៗ ប្រាមដៃចឹងទៅ ចាំងឲ្យមានគន្លាក់កណ្ដាលទៅចាំងចុងវាស្រួចចឹងទៅ យកទៅដោតទៅគេកាប់ជាក្រឡុកដាក់ប្រឆិតៗចឹងទៅឧទាហរណ៍ទីតាំងនៅណាយើងយកទៅដាក់ ចឹងទៅកាប់ជាក្រឡុក ។

វណ្ណៈ ចឹងគេជីកជារណ្ដៅដោតចូល?

យឿនៈ ចាស!គេដោតចូលទៅ បើក្រៅពីរណ្ដៅគេដោតដូចជាសំណាបសន្ទូងបើយើងរត់ទៅមុតគ្មាន សល់ ។

វណ្ណៈ ចឹងពេលមុតមិនអាចទៅណាបានទៀតទេ?

យឿនៈ មុតចុកខ្លាំងណាស់ ។

វណ្ណៈ យ៉ាងម៉េចបានចុក?

យឿនៈ ឬស្សីវាមានពិស ។

វណ្ណៈ យ៉ាងម៉េចបានមានពិស?

យឿនៈ មុតចុកណាស់ ស្លាប់ បើមានលាបជ័រឆក់ផង ។

វណ្ណៈ ចឹងពេលដោតចំរូងអីហ្នឹងគេមានយកមែកឈើគ្របទេ?

យឿនៈ បើនៅវាលស្រែគេយកចំបើងគ្របរោយពីលើ ។

វណ្ណៈ ចឹងយ៉ាប់ជាងគ្រាប់កាំភ្លើងទៀត?

យឿនៈ គ្រាប់កាំភ្លើងស្លាប់ឆាប់ទេ ចំរូងហ្នឹងមុតឈឺណាស់ ។

វណ្ណៈ ចឹងឬស្សីហ្នឹងគេពុះហើយសំរួចស្រួចហើយគេកាត់ប្រហែលជាប្រវែងណាចំនួនពីរតឹកឬយ៉ាង ម៉េច?

យឿនៈ ហ្នឹងហើយកាត់ជាងពីរតឹក កាត់ឲ្យវែងជាងហ្នឹងបន្តិច ព្រោះយើងចាំងកន្លាក់កណ្ដាលបន្តិចយើង សំរួចឲ្យស្រួច ។

វណ្ណៈ ចឹងក្នុងមួយថ្ងៃគេយើងបិតឲ្យបានប៉ុន្មានក្នុងមួយនាក់?

យឿនៈ ក្នុងម្នាក់ឲ្យបាន៣០០ ។

វណ្ណៈ ចឹង៣០០អាចហើយទេ?

យឿនៈ តាមតែយើងបើខំអាចបាន១០០០ផង ធ្វើមួយភ្លេចៗពេលមកខ្ញុំហ្នឹងបានបាត់ហើយត្រឹម ៣០០នោះ យើងមានធ្វើការច្រើនទៀតបង្កបង្កើនផល ។

វណ្ណៈ ចឹងអ្នកដែលទៅសមរភូមិមិនបានដូចជាចាស់ៗគេឲ្យបិតចំរូងចឹងទៅ?

យឿនៈ ចាស!តែចាស់ពេកគេលែងឲ្យធ្វើហើយ ទាល់តែចាស់នៅធ្វើបាន បានធ្វើ ។

វណ្ណៈ ចឹងរបបអាហារអីមានគ្រប់គ្រាន់ដែរ?

យឿនៈ របបចែកឲ្យទាំងអស់គ្នា អត់មានខ្វះខាតទេ ។

វណ្ណៈ ចឹងកាលហ្នឹងមានចាប់បានកងទ័ពវៀតណាមដែរទេ?

យឿនៈ ចាប់បានខ្លះ ។

វណ្ណៈ ចាប់បានគេយកទៅណាទៅ?

យឿនៈ គេយកជូនទៅលើ ។

វណ្ណៈ ចឹងមានដឹងថាខាងទាហានខាងរដ្ឋាភិបាលខាងយួនអីចាប់បានទាហានខ្មែរក្រហមអីគេធ្វើយ៉ាងម៉េចដែរ?

យឿនៈ អត់ដឹង តែពួកខ្ញុំមកនៅមុំបី១០០១ហ្នឹងមុនហ្នឹងបែកទីតាំង១០០១ហ្នឹង ចេញមកឆ្ងាយអីលិចហ្នឹង ទៅឆ្ងាយអីម៉ាឡៃប៉ៃលិនអីហ្នឹង ។

វណ្ណៈ ចឹងមីងទៅខាងម៉ាឡៃប៉ៃលិនទៀត?

យឿនៈ ខ្ញុំទៅម៉ាជួរភ្នំព្រឹកអីហ្នឹង បារាំងធ្លាក់អីហ្នឹងបែកពីទន្លេល្ពៅទៅហ្នឹងទៀត ម្នោះហើយមិនចូលមកនៅមុំបី១០០១ហ្នឹង ភ្នំខ្ពស់ជុំវិញនៅកណ្តាលហ្នឹងសូម្បីតែកាំភ្លើង«ដេស៊ីអា«ហ្នឹងដាក់លើកាណុងហួសបើទម្លាក់កាណុងបុកភ្នំ កាលហ្នឹងកម្លាំងវាស៊ើបមុននិងវាយវាមកតើ អាចមានខ្មែរយើងមកហ្នឹង ពោះជាជុំដីជាសញ្ញាអី ជួនណាឃើញផ្ទះហ្នឹងដាច់ពីគេចូលមកប្រាប់ឲ្យចេញទៅកម្លាំងថ្ងៃហ្នឹងគេបុកចូលមកហើយ ។

វណ្ណៈ ចឹងចូលប្រាប់ប្រជាជនឲ្យចេញ?

យឿនៈ ប្រាប់ប្រជាជនឲ្យចេញប្រពន្ធទ័ពអីហ្នឹង មិនមែនប្រជាជនសុទ្ធទេ ។

វណ្ណៈ ចឹងខាងកម្លាំងខ្មែរក្រហមប្រាប់?

យឿនៈ អត់ទេ ខាងកម្លាំងទាហានរដ្ឋាភិបាល ។

វណ្ណៈ ចឹងខ្មែរគ្នាឯងទាក់ទងនិយាយគ្នាបានដែរ?

យឿនៈ ខ្មែរឮក៏យួននិយាយប៉ែឡាំៗថាឲ្យបងប្អូនចេញទៅ គេវាយថ្ងៃហ្នឹងហើយចឹងណាស់ គេបុកយកទីតាំងហ្នឹងហើយប្រាប់ចឹងតើ ចឹងកាលហ្នឹងមិនចង់វាយគ្នាអីអ្នកក្រោមៗនោះ មកពីអ្នកបញ្ជាខាងលើតាមមើល ។

វណ្ណៈ ចឹងកាលហ្នឹងទាហានខាងរដ្ឋាភិបាលដេញទាហានខ្មែរក្រហមឡើងដល់លើភ្នំដល់ដីថៃអីនោះ?

យឿនៈ តាំងពីឡើងលើភ្នំមក ហើយចុះមកពេលវាយគ្នាកាលហ្នឹងងាប់រៀងៗខ្លួន ។

វណ្ណៈ ចឹងឆ្នាំណាដែលមីងចុះមកនៅស្រុកអន្លង់វែង មកពីខាងម៉ាឡៃអីវិញ?

យឿនៈ មិនដឹងជាឆ្នាំណាទេ ប្រហែលជាឆ្នាំ៨៥-៨៦-៨៧-៨៨ចឹងទៅ ។

វណ្ណៈ ចឹងកាលតាម៉ុក ធ្វើដូវចុះពីលើភ្នំមីងនៅណាដែរ ធ្វើដូវចុះពីអន្លង់វែងមីងនៅណាពេលហ្នឹង?

យឿនៈ កាលហ្នឹងពួកខ្ញុំនៅអូរជីកអន្លង់វែង ។

វណ្ណៈ ចឹងមីងដឹងថា តាម៉ុក ធ្វើផ្លូវចុះពីលើភ្នំនៅឆ្នាំណា?

យឿនៈ ផ្លូវហ្នឹងទើបធ្វើទេ ផ្លូវចាស់មានចុះពីដាំអីមកហ្នឹង ។

វណ្ណៈ តែកាលសម័យសង្គ្រាមថាអត់មានទេ បើចង់ឡើងភ្នំអីកាលហ្នឹងឡើងតាមវិល្លទេ?

យឿនៈ សម័យតាម៉ុក ឈូស ហ្នឹងមិនដឹងជាឆ្នាំប៉ុន្មានទេ មានផ្លូវឈូសឆ្នាំ៨៦-៧៧-៨៨ដឹងទៅ យកអង្ករនៅក្បាលទន្លេរាងជប់ម្លូអីដែលហ្នឹង ។

វណ្ណៈ ទៅយកអង្ករដែរ?

យឿនៈ ហ្នឹងហើយឃ្លាំងនៅហ្នឹង ។

វណ្ណៈ ចឹងមីងមានដឹងថា តាប៉ុល ពត មកនៅហ្នឹងនៅឆ្នាំណាដែរ?

យឿនៈ ប៉ុល ពត មកនៅអន្លង់វែង តាម៉ុក ដាក់គុក មិនដឹងជាឆ្នាំ៨០ប៉ុន្មានទេ តាប៉ុល ពត ស្លាប់ហ្នឹង ។

វណ្ណៈ កាលហ្នឹង ប៉ុល ពត ស្លាប់ហើយប៉ុន្មានឆ្នាំហ្នឹងបានកើតមានសមាហរណ៍កម្មចូលជាមួយរដ្ឋាភិបាល?

យឿនៈ ហ្នឹងហើយ ។

វណ្ណៈ តែមុនចូលជាមួយរដ្ឋាភិបាលខ្ញុំចង់ដឹងទៀតថា ហេតុអីបានជាមានរឿងខ្មែរក្រហមគ្នាឯងសម្លាប់គ្នាដូចជាមានសម្លាប់ តាសុន សេន ទាំងគ្រួសារចឹង មីងមានដឹងទេពេលហ្នឹង?

យឿនៈ មានទំនាស់គ្នាដណ្តើមបុណ្យសក្តិ ចោទថាអានេះចូលខាងនេះខាងនោះចឹងទៅ ពីមុនខ្ញុំដឹងថាប៉ែកខាងលិច តាម៉ុក ចោទ តា សារឿន តា០៦នេះ ថាខាងនេះក្បត់ហើយ ។

វណ្ណៈ ថាខាងត្រពាំងប្រាសាទនេះក្បត់?

យឿនៈ ចាស!ថាខាងត្រពាំងប្រាសាទក្បត់ហើយ ចឹងបានជាខ្ញុំថាដណ្តើមអំណាចគ្នា ដល់០៥ហ្នឹងកម្លាំងមួយចំនួនចេញខ្លោកមានប្អូនជីដូនមួយគាត់ឈ្មោះអីទេ ឈ្មោះ វ៉ន អង្វរតាមគេអូហ្នឹងថា បងអើយមកវិញមក មកសំរួលគ្នាកុំឲ្យបែកគ្នាមានព្រៃម៉ាគីផ្សេងទៀតប្រឆាំងនាំតែហិនហោចគាត់និយាយបេះចុះទៅគាត់មកវិញ ដល់ចូលមកគេចាប់០៥និង០៦ហើយមានតាសែន មានពីណាទៀតប្អូនដប់នាក់ហ្នឹង ។

វណ្ណៈ ចាប់យកសម្លាប់ចោល?

យឿនៈ ចាស ។

វណ្ណៈ ចឹងបន្ទាប់ពីបាញ់ តាសុន សេន ហើយទេ?

យឿនៈ ចាស!ត្រូវហើយ ហើយ សុន សេន ហ្នឹងមិនដឹងជាកម្លាំងពីណាទេសម្លាប់ខ្ញុំក្តាប់មិនបានដែរ តែសម្លាប់មួយពូជទាំងអស់ ។

វណ្ណៈ ចឹងមានន័យថាខាងស្រុកខាងអន្លង់វែងនោះជាកម្លាំងរបស់តាម៉ុក ចោទ?

យឿនៈ ចោទ!ចាស ។

វណ្ណៈ ចឹងខាងកម្លាំងរបស់តា ០៥ តា០៦ ខាងត្រពាំងប្រាសាទនេះជាកម្លាំងរបស់តាប៉ុល ពត?

យឿនៈ ចោទគ្នាចឹង មានទំនាស់គ្នា តាគុន អី ។

វណ្ណៈ តែអ្នកនៅខាងអន្លង់វែងគេនិយាយថា តា០៥តា០៦ទៅសម្លាប់គ្រួសារ សុន សេន នៅអន្លង់វែងហ្នឹងតែមិនថាពិតវាមិនពិត?

យឿនៈ រឿងហ្នឹងយើងក្តាប់វាមិនបានទេ វាមិនបានឃើញ កាលមុននៅធ្វើមេបន្ទាប់ៗគ្នាគ្រប់គ្រងកម្លាំងតែមួយហ្នឹង ពេលឡើងមកចឹងទៅរៀនកន្លែងលោក សុន សេន ចឹងទៅ ហើយតាខៀវ សំផន គាត់នៅក្រសួងការបរទេសគាត់មិនសូវដឹងទេ បើ សុន សេន ខាងនយោបាយបន្ទាប់ៗគ្នាពីតាប៉ុល ពត មកចឹងណាស់ តាប៉ុល ពត មេធំៗគេទៅរៀនហ្នឹងវាតគ្នាចឹង ។

វណ្ណៈ ចឹងកាលហ្នឹងមានកម្លាំងបែងចែកពីអន្លង់វែងហ្នឹងមឹងមកនៅតាមតា០៥ តា០៦ហើយ?

យឿនៈ ខ្ញុំនៅខាងអូរស្មាច់ ។

វណ្ណៈ អូរស្មាច់ខាងតាម៉ុក នោះទេ?

យឿនៈ អត់ទេ តាម៉ុក ខាងអន្លង់វែង ។

វណ្ណៈ ចឹងនៅអូរស្មាច់ខាងត្រពាំងប្រាសាទដែរ?

យឿនៈ ចាស!អូរស្មាច់ត្រពាំងប្រាសាទទៅខាងនេះ ខាងនោះទៅអន្លង់វែង ប្អូនៗខ្ញុំគេនៅអន្លង់វែងទោះបីវាចូលផ្ទះខ្ញុំនៅអូរស្មាច់អូរជីកនេះ វាមកតែមួយភ្លែតទេ មួយរយៈហ្នឹងគេថាកម្លាំង០៥សុទ្ធតែក្បត់ហើយ ថាក្បត់ខ្មោចយក៍អីបងប្អូនចូលមិនបាន ខ្ញុំអត់ខ្លាចទេខ្ញុំនិយាយចឹងវាចូលមកមួយភ្លែត ។

វណ្ណៈ ចឹងបងប្អូនចង់នាំហៅទៅខាងនោះវិញ?

យឿនៈ ចាស!ខ្ញុំថាគ្មានទំនាស់អីក្រៅពីដណ្តើមអំណាចគ្នាហ្នឹង ។

វណ្ណៈ ចឹងកាលមីងចុះមកនៅអូរស្មាច់ហ្នឹងនៅឆ្នាំណា?

យឿនៈ ៨០ ឬ ៩០ ហើយដឹង ។

វណ្ណៈ ចឹងកាលចុះមកជំនាន់អ៊ុនតាក់អីទេ?

យឿនៈ ចាស ។

វណ្ណៈ ចឹងមីងមានបានបោះឆ្នោតទេ?

យឿនៈ ចោះតើកាលហ្នឹង ផ្តាច់ខ្លួនមកបោះឆ្នោតនៅត្រពាំងប្រាសាទ ។

វណ្ណៈ ចឹងកាលមីងចុះមកមុនអ៊ុនតាក់ឬដំណាលអ៊ុនតាក់?

យឿនៈ ស្រករគ្នាហ្នឹង កាលអ៊ុនតាក់ខ្ញុំនៅអូរជីក ។

វណ្ណៈ ចឹងត្រូវហើយតាម៉ុក ចាប់ផ្តើមធ្វើផ្លូវឆ្នាំ៩០ជាងចុះមក?

យឿនៈ ចាស ។

វណ្ណៈ កាលវៀតណាមដកទៅស្រុកវិញនៅសល់តែខ្មែរៗវាយគ្នាហ្នឹង មិនសូវខ្លាំងខ្លាចទេ អាចនិយាយគ្នាបាន?

យឿនៈ ហ្នឹងហើយ កាលឆ្នាំ៩៧កូនខ្ញុំទើបកើត នៅអូរជីកហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងមីងមានដឹងថា មានមូលហេតុអីបានជាកម្លាំងខ្មែរក្រហមព្រមចរចារជាមួយកម្លាំងរដ្ឋាភិបាល មីងមានបានដឹងទេរឿងហ្នឹង?

យឿនៈ ខ្ញុំមិនសូវដឹងដែរ តាមខ្ញុំដឹងពីមុនសូម្បីតែសម្តេចហ៊ុន សែន ក៏ខ្មែរក្រហមដែរ ដូច្នេះបើគេមានវិធានការចឹងទៅដើម្បីបង្រួបបង្រួមខ្មែរគ្នាឯងកុំឲ្យវាស្លាប់ច្រើនពេក រួបរួមចឹងក៏វាល្អដែរ យើងមានផ្ទះសំបែងយើងលែងរត់លែងលូន ពីមុនមកឆ្នាំងបាយដាំហូបរួចហើយចងជាប់និងខ្នងហើយអង្ករប្រកទៃ ។

វណ្ណៈ ចឹងគ្មានផ្ទះដីស្រែចម្ការធំៗទេ?

យឿនៈ ចម្ការកាប់បានតែមួយរ៉ៃពីររ៉ៃហ្នឹង ធ្វើចឹងទៅហូបទៅ ។

វណ្ណៈ ចឹងមានប្រជាជនមានគ្រោះថ្នាក់ដោយសារយើងកាប់យកដីចម្ការហ្នឹងដែលឬមួយយ៉ាងម៉េច?

យឿនៈ អត់មានដែលផ្ទុះមីនគ្រោះថ្នាក់អីទេ កាលដែលយើងនៅព្រៃណាស់ ។

វណ្ណៈ ចឹងយើងសុទ្ធតែអ្នកចេះដឹងមានបទពិសោធថាកន្លែងមានមីនកន្លែងណាគ្មានមីន?

យឿនៈ ហ្នឹងហើយ ចេះតែនាំគ្នាធ្វើរៀបចំតាមអង្គភាពមួយចឹងទៅណាស់ ហើយមិនចេះលួចអីគ្នាទេ ទោះបីទុកចោលគ្មានចេះយកដូចឥឡូវនេះទេ ឥឡូវមិនបានទេ ដាំណាំដាំដុះទុករណ្តូករណែលពេញហ្នឹងអី ។

វណ្ណៈ ចឹងមីងមានដឹងថា ប្រធានកងពលណាខ្លះដែលនាំចលនាចូលជាមួយរដ្ឋាភិបាល?

យឿនៈ អ្នកនាំចលនាផ្តាច់ខ្លួនមានតា ជុំ ជាតិ តា កែវ គាត់ផ្តាច់ខ្លួនទៅមុនឲ្យយើងនៅក្រោយណាពួកហ្នឹងក៏តាម៉ុក យកទៅដែរ សូម្បីតែនៅអូរជីកគ្រួសារខ្ញុំក៏ដោយ គេថាយកទៅឲ្យនៅកន្លែងមន្ទីរ ។

វណ្ណៈ ពេលយើងចូលមកវិញតាម៉ុកយកទៅ?

យឿនៈ គេឲ្យទៅនៅកន្លែងមន្ទីរហ្នឹង ម្ចោះហើយខ្ញុំអាប្អូនខ្ញុំវាមកហ្នឹង ថាឲ្យយកគ្រួសារឲ្យទៅធ្វើការនៅកន្លែងមន្ទីរ ខ្ញុំថា បើឯងចង់យកទៅយកទៅទាំងអស់ទៅ បើថាទៅតែគាត់មិនឲ្យទៅទេ ទោះបីគាក៏ដោយយកទៅទាំងគ្រួសារទៅ ទៅតែឯងមិនឲ្យទៅទេ ដល់នេះថា អាហ្នឹងមាត់រីងណាស់អ៊ីខ្ញុំថាបើថាមាត់រឹងយកទៅវាយចោលទៅ ខ្ញុំអត់មានខ្លាចទេ ។

វណ្ណៈ ចឹងមីងហ៊ានតវ៉ាជាមួយតាម៉ុកទេ?

យឿនៈ ខ្ញុំមិនខ្លាចទេ ថ្នាក់ប៉ុណ្ណាក៏ដោយកុំឲ្យតែខ្ញុំខុស ខ្ញុំនិយាយតែម៉ាត្រូវទេ ដឹកនាំប៉ុណ្ណាក៏ដោយកុំឲ្យតែយើងធ្វើខុសខ្ញុំមិនខ្លាចទេ ធ្វើអីក៏ដោយសព្វថ្ងៃក៏ដោយកុំឲ្យតែយើងធ្វើខុសច្បាប់ ។

វណ្ណៈ ចឹងតាជុំអីចូលមកវិញ តាម៉ុក គាត់អត់យកទៅសម្លាប់អីដែលទេ?

យឿនៈ តាជុំ តាកែវ ទៅធ្វើផ្ទះតាម៉ុកមួយរយៈហ្នឹងទៅ ។

វណ្ណៈ ឬមួយតាម៉ុក គាត់គិតថាបើចេះតែសម្លាប់បន្តទៀតធ្វើមនុស្សចេះតែបះបោល?

យឿនៈ ហ្នឹងហើយ វាអស់កន្លងមកអ្នកណាអ្នកចលនាកម្លាំងកូនប្រជាជនឲ្យចេញមក គេមិនបាននៅបម្រើម៉ែឪគេ យើងត្រូវគិតផងផាកសម្លាប់ៗផាប់ផុតពូជអស់ទៅ ខ្ញុំមិនខ្លាចទេខ្ញុំថាចឹង ប៉ុណ្ណាក៏ដោយ ។

វណ្ណៈ ចឹងមីងមានគិតថា របបដាក់រួមមិនមានការចាយលុយអីចឹងហើយឥឡូវមានលុចាយអីចឹង មីងគិតថារបបមួយណាវាស្រួលជាង?

យឿនៈ របបគេមិនចាយលុយគេស្រួលប្រើកម្លាំង តែស្រួលប្រើកម្លាំងគេខបត្តមចឹង បើដូចយើងឥឡូវបើយើងរំលាយមកតាំងពីយូរយើងត្រូវមានរបបចាយលុយយើងខំនាំគ្នារកស៊ីបង្កបង្កើនផលដើម្បីចិញ្ចឹមជីវិតកូនចៅយើងប្រហែលជាមិនក្រចេះទេតាមមើល ខ្ញុំគិតឃើញចឹង បើយើងប្រៀបធៀបជាមួយគេអ្នកនៅខាងក្នុងគេរកស៊ីនៅស្រុកនៅទេសគេមានដល់ឯងនៅព្រៃនេះទើបផ្ដាច់ខ្លួនបាន១០ឆ្នាំជាង យើងនៅក្រជាងគេហើយ ក្នុងទស្សនៈខ្ញុំមួយមិនចង់ទៅស្រុកទេព្រោះទៅស្រុកដីមានបន្តិចបន្តួចបងប្អូនចែកគ្នាអស់ហើយ ហើយបងប្អូនម្យ៉ាងខ្ញុំធ្លាប់ទៅទាំងគ្រួសារចឹង ខ្ញុំទៅបានពីរបីដងខ្ញុំទៅធ្វើបុណ្យអីនោះ ឃើញយើងអ្នកព្រៃទៅមុខមិនសូវរីកប៉ុន្មានទេ ចិត្តល្អបានតែ៦ទៅ៧ថ្ងៃតែរាបលខែឡើងអត់ទេ ខ្លាចយើងទៅដណ្ដើមកេរ្តិ ខ្ញុំនិយាយស្រេចថា ប្អូនបងមកនេះ មិនបានមកទាមទារកេរ្តិកពីឪពុកម្ដាយអីទេ ទោះបីគាត់ទុកឲ្យកូននេះៗក៏បងមិនយកដែរ ធ្វើម៉េចឲ្យចេះតែសាមគ្គីគ្នាបងប្អូនឯងដែលនៅប៉ុន្មាននាក់ចុះ បងមិនខ្វះទេទឹកដី បងនេះដើម្បីមនោសញ្ចេតនាបងប្អូននិងធ្វើបុណ្យឪពុកម៉ែ យើងរួមគ្នាអត់មានចង់បានកេរ្តិអីទេ មកលេងមិនដែលឃើញ ទស្សនៈខ្ញុំចឹង ខ្ញុំក្រខ្ញុំមានក៏ខ្ញុំមិនមកទាមទារទឹកដីនេះដែរ ដីស្រុកនេះវាចង្អៀតណាស់ ។

វណ្ណៈ៖ ចឹងមកដល់សព្វថ្ងៃហ្នឹងជាមួយអ្នកជិតខាងមីងមានទំនាក់ទំនងយ៉ាងម៉េចដែរ?

យឿន៖ ខ្លះក៏យើងសាមគ្គីគ្នាធំទូលាយទៅ ខ្លះក៏មានបញ្ហាបន្តិចបន្តួចដែលណា ដូចថាទឹកដីអីចឹង ដូចថាខ្ញុំខំកាប់ស្ការមកដីខ្ញុំនៅខាងនោះ ជិតផ្ទះចៅហ្វាយស្រុកណា ពីផ្ទះហ្នឹងមករហូតដល់ផ្ទះនេះ ផ្ទះជិតតូចលក់ផុងវែងហ្នឹង ដីខ្ញុំមកនៅដីគេដែលទេ ម្ចាស់គេខ្លះទៅស្រុកខ្លះស្លាប់អីចឹងទៅខ្ញុំដោះដូរដីខ្ញុំនៅនោះ បើខ្ញុំនៅនោះខ្ញុំមានឡានជិះតាំងពីយូរហើយ ខ្ញុំសុខចិត្តមកយកដីនេះវិញ ខ្ញុំចង់បានស្រះនេះខ្ញុំគិតថាមានកូនច្រើន ខ្លាចគេអត់មានអភិវឌ្ឍន៍ដូចឥឡូវនេះ មានកាយប្រឡាយមានជីកអណ្តូងចឹង ចង់បានកន្លែងមានទឹកស្រួលឲ្យកូនដងកុំពិបាក ។

វណ្ណៈ៖ ចឹងបើមីងយកដីជិតសាលាស្រុកនោះមីងបានថ្លៃជាង?

យឿន៖ ដីខ្ញុំនៅនោះបានថ្លៃសុខចិត្តមកដីនេះវិញ មានអីទៀតមានតែស្រះ ខ្ញុំធ្វើរបងធ្វើផ្លូវចែកឲ្យកូនអស់ហើយ ។

វណ្ណៈ៖ ចឹងមីងបានដីចែកគ្រប់កូនដែរ?

យឿន៖ ចាស!ចឹងបានថាយ៉ាប់ណាស់មនុស្សយើងម្នាក់ៗ ទីផ្សារត្រពាំងប្រាសាទនេះប្តីខ្ញុំ គាត់ធ្វើអីមកគេឲ្យគាត់ធ្វើមេឃុំនៅនេះឯង ជាអ្នករៀបរយទីផ្សារហើយមិនចង់បានបើខ្ញុំនៅផ្សារក៏បានដី ដីប្អូនអីមាននៅហ្នឹង នឹកឃើញកូនច្រើនគិតថាវាលូង់ក៏ថាបានដែរ កូនច្រើននៅផ្សារពិបាកកូនទារស៊ីអីយើងវាមិនសូវមានលុយកាក់ សុខចិត្តមកនៅឆ្ងាយ បើយកតែពីរបីផ្លង់យកទុកលក់ដល់ឥឡូវឬទុកជួលឲ្យគេក៏ខ្ញុំមិនអត់ដែរ ។

វណ្ណៈ៖ ចឹងពាក់ព័ន្ធនិងការរកស៊ីអីចឹងក្នុងមួយឆ្នាំៗ ដូចថាឆ្នាំនេះត្រូវធ្វើអី ឆ្នាំក្រោយត្រូវធ្វើអីចឹង មីងមានដែលពិភាក្សាជាមួយប្តីមីងថា យើងគិតធ្វើអីឆ្នាំនេះ គំនិតចឹងៗមីងដែលពិភាក្សាជាមួយប្តីទេ?

យឿន៖ មានពិភាក្សាគ្នាតើ ថាឆ្នាំនេះយើងត្រូវធ្វើអី មិនថាតែប្តីទេនិយាយជាមួយកូនចៅទៀត កូនវាអ្នកធ្វើ យើងម៉ែឪបានជួយតែយោបល់ទេ ទឹកចិត្តគំនិតឲ្យវា អ្នកដែលទៅធ្វើកូន ។

វណ្ណៈ៖ ចឹងមានការពិភាក្សាញឹកញាប់ទេ?

យឿន៖ និយាយគ្នារាល់ថ្ងៃ ឆ្នាំនេះបានតិចគិតពិភាក្សាគ្នាថា ខ្មាស់ពួកក្រោយ អ្នកនៅកំពង់ចាមមកមកក្រោយមើលពួកហ្នឹងមកធ្វើតែកាប់បិតពូចៅទេ ស្រូវគេបួនប្រាំហាត់ ហើយឃើញភ្ជួរគោយន្តមើលបានស្រូវបួនដប់បេយ៉ាងម៉េចទៅ ចេះតែនិយាយគ្នាចឹង ។

វណ្ណៈ៖ ចឹងបញ្ហាដីធ្លីមានពាក់ព័ន្ធជាមួយក្រុមហ៊ុនរឹបអូសយកយ៉ាងម៉េចដែរ ក្រោយពីមានការចុះវាស់វែងដីមក?

យឿនៈ រឿងរាស់វែងដី ខ្លះបានប្ដូរខ្លះមិនទាន់បានទេ ចឹងបានថា សម្ដេចហ៊ុន សែន ដាប់ហើយដំរុញឲ្យចុះមកទម្លាក់ផ្លង់តែមិនទាន់ឃើញផង មិនដឹងជាយ៉ាងម៉េចដែរ មិនដឹងប៉ះឬមិនប៉ះចេះតែធ្វើ ចឹងទៅរឿងរបស់គេធ្វើម៉េចក៏ធ្វើទៅ ថ្ងៃណាគេយកទៅថ្ងៃណាគេមិនយកយើងធ្វើចឹងទៅ ។

វណ្ណៈ ចឹងក្មេងៗសព្វថ្ងៃហ្នឹងដូចជាឃើញចាស់ៗចេះគោរពអីទេឬមិនសូវចេះគួរសមអីទេ?

យឿនៈ ទេ គួរសមដែលតើ យើងអប់រំវាទៅ ឃើញចាស់ទុំអីវាចេះជំរាបសួរដូចគ្នា ។

វណ្ណៈ ចឹងនៅក្នុងភូមិហ្នឹងមានក្មេងពាលាដើរហិតកែវអីដើរវាយកាប់ចាក់អីទេ?

យឿនៈ ភូមិហ្នឹងដូចជាមិនសូវមានទេ រឿងហិតកែវលេបថ្នាំញៀនអីណាស់ តែមានរាំគុងបាស់អីហ្នឹង កូនមេឃុំអីហ្នឹងវាឈ្លើយវាវាយគ្នាអីចឹងទៅ ។

វណ្ណៈ ចឹងបើបើរាល់ថ្ងៃមីងមានបញ្ហាដូចជាកូនចៅឬមានរឿងដីធ្លីកើតឡើង មីងអាចទុកចិត្តច្បាប់យើងសព្វថ្ងៃបានទេ?

យឿនៈ ទុកចិត្ត បើសិនជាមានបញ្ហាអីយើងរកផ្លូវច្បាប់ហ្នឹងហើយ ។

វណ្ណៈ ចឹងជីវភាពមីងរាល់ថ្ងៃហ្នឹងយ៉ាងម៉េចដែរ ក្រ មានឬធម្យម?

យឿនៈ ជីវភាពខ្ញុំសព្វថ្ងៃដូចថាឲ្យមានក៏វាមិនមានតែឲ្យក្រក៏មិនក្រ ល្មមតែម៉ារស់ទៅជាមួយគេឯងចឹងណាស់ ។

វណ្ណៈ ចឹងខាងរដ្ឋាភិបាលឬមានអង្គការណាមកចុះណែនាំរឿងកសិកម្ម សហគមន៍ផ្សេងៗអីមីងមានដែលចូលរួមអីដែរ?

យឿនៈ មាន ។

វណ្ណៈ មីងធ្លាប់ចូលរួមប្រជុំដែរ?

យឿនៈ ចាស!គេឲ្យចឹញ្ចឹមនេះចិញ្ចឹមនោះអីចឹងទៅ មានចូលរួមប្រជុំជាមួយគេ ។

វណ្ណៈ ចឹងមីងគិតថា មានអង្គការមកជួយចែករំលែកបទពិសោធន៍ចឹង មីងគិតថាល្អឬមួយយ៉ាងម៉េច?

យឿនៈ ចាស!ខ្ញុំគិតថាល្អហើយគេមកពន្យល់ឲ្យយើងយល់ ។

វណ្ណៈ ចឹងមីងសព្វថ្ងៃហ្នឹង មីងកាន់សាសនាអីដែរ?

យឿនៈ កាន់សាសនាព្រះពុទ្ធ ។

វណ្ណៈ ចឹងមីងយល់យ៉ាងម៉េចដែលសាសនាព្រះពុទ្ធយើង?

យឿនៈ ខ្ញុំមិនសូវយល់ទេ តែដឹងថាតាំងពីកើតពោះម៉ែមកដឹងថាសាសនាព្រះពុទ្ធរហូតហើយ មានសាសនាផ្សេងមកប្រាប់មកពន្យល់ចឹងដែលតែមិនចាប់អារម្មណ៍ ចង់បានតែសាសនាព្រះពុទ្ធមួយហ្នឹងឯង ។

វណ្ណៈ  ចឹងពេលមីងកាន់បាយសម្លនៅពេលមានភ្ជុំបិណ្ឌ  តើមីងប្រាថ្នាចង់បានអីដែរ?

យឿនៈ ខ្ញុំចង់បានឲ្យបានសុខសប្បាយរកស៊ីមានបានឲ្យបានដល់ឪពុកម្តាយជីដូនជីតាម៉ាកុង  កុំឲ្យមានខបស័ក្តកុំឲ្យមានកើតសង្គ្រាមចឹងទៀត  ឲ្យមានសន្តិភាពរហូត ។

វណ្ណៈ  ឥឡូវមានវត្តប៉ុន្មានហើយ?

យឿនៈ មានវត្តច្រើនណាស់  អូត្រាវក៏វត្តមួយ  វត្តលើ  ឥឡូវមានជាង១០វត្តហើយ ។

វណ្ណៈ  ចឹងសាលារៀនអីមានដល់កំរិតណាដែលនៅស្រុកហ្នឹង?

យឿនៈ សាលារៀនពួគេថាមានត្រឹមថ្នាក់ទី១២ដែរ  ពីមុនទៅរៀននៅអន្លង់វែង  ទី១២ទៅអន្លង់វែង ឥឡូវមាននៅនេះ ។

វណ្ណៈ  ចឹងខ្ញុំចង់សួរបកទៅប្រាសាទព្រះវិហារបន្តិចដោយសារសម័យខ្មែរក្រហមហ្នឹង  ចង់ដឹងថានៅលើប្រាសាទហ្នឹងមានទាហានថៃឈរលើប្រាសាទហ្នឹងដែលឬមួយយ៉ាងណា?

យឿនៈ កាលសម័យសង្គ្រាមខ្ញុំធ្លាប់ឆ្លងកាត់តាមហ្នឹងដែរ  តាមវាលឥន្ទ្រីយ៍ហ្នឹង ។

វណ្ណៈ  ចឹងនៅវាលឥន្ទ្រីយ៍ហ្នឹងមានទាហានថៃឈរនៅហ្នឹងទេ?

យឿនៈ កាលមុនមិនមានទេ ។

វណ្ណៈ  ចឹងរឿងផ្ទះក្រហមហ្នឹង  តាម៉ុកជាអ្នកធ្វើឬខាងថៃធ្វើ  ហើយមានផ្លូវចុះមកហើយមានផ្សារជាប់ជើងប្រាសាទហ្នឹងហើយបានឡើងមកប្រាសាទ  មីងមានបានដឹងទេ?

យឿនៈ ខ្ញុំមិនសូវដឹងដែរ  ពេលឆ្លងកាត់ខ្ញុំឆ្លងខាងព្រះវិហារយើងមកខាងនេះ  ហើយថៃទៅខាងនោះយើងដើរប្រឡោះកណ្តាល ។

វណ្ណៈ  ចឹងកាលហ្នឹងយើងមានផ្លូវឡើងព្រះវិហារទេ?

យឿនៈ យើងមិនទាន់មានទេ  យើងមានផ្លូវធម្មតា  យើងធ្វើផ្លូវកៅស៊ូមកពីថៃដែរ ។

វណ្ណៈ  ចឹងផ្លូវកៅស៊ូហ្នឹងគេធ្វើនៅឆ្នាំណា  ផ្លូវកៅស៊ូពីថៃមក?

យឿនៈ អត់ដឹង ។

វណ្ណៈ  ឥឡូវប្រាសាទព្រះវិហារនៅតុលាការក្រុងឡាអេ  តុលាការអន្តរជាតិគេអានសាលក្រមឡើងវិញថាប្រាសាទព្រះវិហារនិងដីជុំវិញព្រះវិហារជារបស់កម្ពុជា  តែថៃរាល់ថ្ងៃហ្នឹងប្រជាជនមួយចំនួនចេះតែថារបស់វា  ហើយឥឡូវហ្នឹងទាហានថៃនៅតែឈរជើងនៅកន្លែងដដែល?

យឿនៈ ខ្ញុំវាមិនសូវដឹងដែរ  តែយើងដឹងថាថៃមានទឹកដីពិតប្រាកដណាមកសុំដីគេជ្រាកកោនសោះយូរៗបង្កើតសម្តេចក្រាញ់ចង់លេបយកទឹកដី  ពេលបារាំងមកនេះមានការរើបម្រាស់បានចែកឲ្យវិញ  យើងមើលប្រវត្តិសាស្រ្តដឹងហើយ  តាមចាស់ៗគាត់និយាយចឹង  ទឹកដីយើងស្តាយណាស់មើលសមុទ្រអីគេយកអស់រលីង  វៀតណាមយកខ្លះថៃយកខ្លះ  រួមដីអស់ហើយកូនចៅៗ

ក្រោយមិនដឹងជាយ៉ាងម៉េចទេ អត់ពីចាស់ៗ ទៅប្រវត្តិសាស្ត្រហ្នឹងវាជូរចត់ណាស់ ថៃតាមមើលជាជនជាតិភាគតិចរបស់ចិន ។

វណ្ណៈ តែបើយើងឈរលើស្មារតីទាំងអស់គ្នា ទៅមុខទៀតពិបាកយកដែលដោយសារថា អង្គការសហប្រជាជាតិគេទទួលស្គាល់យើងដែរ ឥឡូវនេះ ។

យឿនៈ យើងប្រគល់ឲ្យអង្គការយូនីស្គូអស់ហើយ ។

វណ្ណៈ តែនៅមានបញ្ហាបាត់បង់បន្តិចបន្តួចនេះវាមិនអាចជៀសផុតទេ វាចេះតែមានហើយមីង?

យឿនៈ ចាស!សូម្បីតែ៨០៨ហ្នឹងកាលពួកខ្ញុំនៅហ្នឹង កាលខ្ញុំនៅដឹកជញ្ជូនមកបង្គោលវាដាក់ចេះវាចាក់បួនជ្រុងចេះមួយម៉ែត្របួនជ្រុងមានបង្គោលកណ្តាល វាគាស់ចោលវាកាប់ព្រៃបំពានទៅខាងមុខទៀត វារំកិលបង្គោលព្រំដែន ចឹងបានខ្ញុំថាទំរាំចប់សង្គ្រាមថៃវាយកដីអស់ហើយ វារំកិលវាគាស់អាហ្នឹងទៅវាទៅចាក់ខាងមុខទៀតចឹងទៅណាស់ កាលមុនវាចាក់តែមួយម៉ែត្របួនជ្រុងក្រោយវាចាក់ពីរម៉ែត្របួនជ្រុង ឥឡូវអត់ពីសម្តេចទៀតហើយវាចេះតែរំលោភទៀតទៅ ។

វណ្ណៈ ចឹងទាក់ទងនិងជនអន្តោប្រវេសម្តង ឥឡូវបើជនអន្តោប្រវេសជិតខាងគេមករស់នៅក្នុងស្រុកភូមិយើង នៅជិតក្បែរផ្ទះមីងកាន់តែច្រើនទៅ មីងសប្បាយចិត្តទេ?

យឿនៈ អត់ទេ ។

វណ្ណៈ ហេតុអីមីង?

យឿនៈ មិនសប្បាយទេ កូនចៅយើងថ្ងៃមុខថ្ងៃក្រោយមិនដឹងជាយ៉ាងម៉េច យើងទៅជានៅក្រោមស្នាបរបស់គេគ្របដណ្តប់ទាំងអស់គ្មានសិទ្ធសេរីភាពរស់នៅស្តាប់តាមគេ ។

វណ្ណៈ ចឹងបើមានជនជាតិផ្សេងមកទិញដីក្បែរហ្នឹងមកនៅជិតមីងក៏មីងមិនសប្បាយចិត្តដែរ?

យឿនៈ ចាស ។

វណ្ណៈ ចឹងបើខ្មែរគ្នាឯងវិញ?

យឿនៈ ខ្មែរគ្នាឯងវាមិនអីទេ កុំឲ្យតែបរទេសយូរៗទៅយើងទៅជាជនជាតិភាគតិចរបស់គេ ហ្នឹងហើយតែបើធ្វើម៉េចសង្គមវាត្រូវទៅចឹងហើយ ទឹកត្រជាក់ត្រីកុំចឹងគេយ៉ាងម៉េចយើងយ៉ាងម៉េច ខ្ញុំខ្ជិលគិតវែងឆ្ងាយខ្ញុំអាយុប៉ុននេះហើយ រស់កាលណាបាន១០ទៅ២០ឆ្នាំខាងមុខទៀតចុះសម័យឥឡូវជាតិពុលជាតិគីមីច្រើនណាស់ សម័យម៉ែឪយើងបានអាយុ១០០អាយុ៩០ឥឡូវបាន៦០ជាងតែប៉ុណ្ណឹង អាចរស់បានបួនដប់ឆ្នាំទៀតអរហើយ ម្យ៉ាងជាតិពុលជាតិគីមីជាតិម្សៅវាពេញខ្លួនអស់ហើយ ហើយចំណីអាហារតាមផ្សារអីសុទ្ធតែមានជាតិគីមី ដំណាំដាំដុះក៏យកពីគេមក ខ្ញុំថារស់មិនយូរទេ សម័យឥឡូវនេះមិនដូចពីដើមទេ ឥឡូវនេះយើងមើលទៅ

សុទ្ធតែជាតិពុលទាំងអស់ ឥឡូវខ្ញុំមិនគិតអីច្រើនថ្ងៃណាផងរាប់ កូនវានាំគ្នារស់នៅទៅមិនដឹងជាធ្វើម៉េចទេ គេទៅយ៉ាងម៉េចយើងចឹងទៅ ខ្ញុំគិតចឹងឥឡូវ ។

វណ្ណៈ ចឹងខ្ញុំដូចជាជួបមីងជិតពីរម៉ោងហើយ អរគុណមីងច្រើន មីងអីចង់បន្ថែមទៀតទេ?

យឿនៈ អត់មានអីទេ ។

វណ្ណៈ ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

យឿនៈ ចាស ។

**ចប់**